# សង្កេតការណ៍ ៤

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# អៀង ធីរិទ្ធ ហៅសមមិត្ត ភា

ខែវិច្ឆិកា ឆ្នាំ២០១១

## មាតិកា


សវនាការថ្ងៃទី១៩-២០ ខែតុលា

ការកំណត់សំណងជាក់លាក់ ១

សម្ភាសន៍ អៀង ធីរិទ្ធ ៦

ការវិវឌ្ឍថ្មីៗរបស់សាលាក្ដីខ្មែរក្រហម

អ្វីទៅជាវិធានការសំណង ១៣

ការបំបែកសំណុំរឿង០០២ ១៧

ការលាលែងពីតំណែង ២១



ក្រុមសង្កេតការណ៍ :

គីម ម៉ារីយ៉ាន, ឌី សុជាតា,

លីម ជ័យទត្ត និង ចាន ប្រាថ្នា


មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌ ◆ www.dccam.org



អៀង ធីរិទ្ធ ជួបគណៈប្រតិភូស៊ុយអែដ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភព ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្ដីពីការកំណត់ជាក់លាក់នូវសំណង និង កាយសម្បទារបស់ អៀង ធីរិទ្ធ

## ថ្ងៃទី១៩-២០ ខែតុលា ឆ្នាំ២០១១

*ដោយ ឌី សុជាតា និង លីម ជ័យទត្ត*

### សេចក្ដីផ្ដើម

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបើកសវនាការមួយដើម្បីផ្ដល់ឱកាសឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដាក់សំណើបំពេញបន្ថែមស្ដីពីការស្នើសុំសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំង ១៧៤៥ នាក់ ដែលទើបត្រូវបានទទួលស្គាល់នាពេលថ្មីៗនេះ ។ សវនាការនេះអនុញ្ញាតបន្ថែមឲ្យសហមេធាវីនាំមុខលើកឡើងពីខ្លឹមសារជាក់លាក់ និងគម្រោងសំណងដែលមានកិច្ចសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះដើម្បីដាក់ជូនទៅអង្គជំនុំជម្រះពិនិត្យ និងសម្រេច ។

ភ្ជាប់នឹងបញ្ហាខាងលើ អង្គជំនុំជម្រះសាលាដំបូងក៏បានបើកសវនាការដេញដោលទាក់ទងនឹងសម្បទា បញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ សវនាការនេះធ្វើឡើងដើម្បីពិចារណាទៅលើរបាយការណ៍របស់អ្នកជំនាញថ្មីផ្នែកវិកលវិទ្យាចំនួនបួនរូបផ្សេងទៀត ដែលចាត់តាំងដោយអង្គជំនុំជម្រះដើម្បីបំពេញបន្ថែមទៅលើសេចក្ដីសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ចន ខាំប៊ែល ពាក់ព័ន្ធនឹងសម្បទាបញ្ញា ស្មារតី និងប្រព័ន្ធសរសៃប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ជនជាប់ចោទ អៀង ធីរិទ្ធ ដែលធ្លាប់ត្រូវបានអះអាងដោយលោកសាស្ត្រាចារ្យ ចន ខាំប៊ែល ថាមានជំងឺចុះខ្សោយធ្ងន់ធ្ងរផ្នែកប្រព័ន្ធប្រសាទ អាចជាបញ្ហាចំពោះការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ និងមិនអាចចូលរួមបានពេញលេញនៅក្នុងសវនាការនាពេលខាងមុខទៀត ។

សវនាការនៅថ្ងៃទី១៩ និងថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ព្យាយាមដោះស្រាយរាល់បញ្ហាប្រឈមដែលអាចកើតមានឲ្យបានរួចរាល់មុននឹងឈានចូលទៅដល់សវនាការលើអង្គសេចក្ដីដែលនឹងត្រូវនៅថ្ងៃទី២១ ខែវិច្ឆិកា ខាងមុខនេះ ក្នុងដំណើរការនីតិវិធីសវនាការទាំងពីរថ្ងៃនេះ គឺមិនមានវត្តមានរបស់ជនជាប់ចោទ ខៀវ សំផន និងមេធាវីការពារក្ដីរបស់ខ្លួនឡើយ ។

### ១) ការកំណត់ជាក់លាក់នូវសំណង

នៅក្នុងអនុស្សរណៈកាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផ្ញើការបញ្ជាក់បឋមអំពីខ្លឹមសារជាក់លាក់នៃសំណងដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្ដឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាព ដោយអនុលោមតាមវិធាន៨០ស្ទួន(៤) និងវិធាន២៣ ស្ទួនបួន(៣)(ខ) នៃវិធានផ្ទៃក្នុង និងស្នើឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបំពេញបន្ថែម ធ្វើបច្ចុប្បន្នភាព និងកែសម្រួលខ្លឹមសារបឋមនៃសំណងនៅក្នុងករណីចាំបាច់ ។[1] ការកំណត់សំណងជាក់លាក់ គឺជាការតម្រូវពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវមានកិច្ចសហការស្អិតរមួតជាមួយនឹងមន្ត្រីគ្រប់គ្រងគម្រោងកម្មវិធីសំណងរបស់អង្គភាពគាំពារជនរងគ្រោះ ដើម្បីធានាថាបណ្ដឹងទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់មានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស មានតួលេខច្បាស់លាស់ និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់

---

[1] *អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន២៣ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង" ឯកសារ E125 ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ។*

អនុវត្តគម្រោងសំណងដែលបានស្នើឡើង[២] ឬទេ ។

## ក) អំណះអំណាងស្តីពីសំណងជាក់លាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី

### ១) ភាពលំបាកក្នុងការឲ្យនិយមន័យលើពាក្យសំណងជាក់លាក់

នៅក្នុងសវនាការថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យលើកឡើងទាក់ទងនឹងខ្លឹមសារចំពោះអត្ថន័យនៃពាក្យសំណងជាក់លាក់ដែលខ្លួនបានធ្វើការបំពេញបន្ថែមធ្វើបច្ចុប្បន្នភាព និងធ្វើការកែប្រែរួចរាល់ដើម្បីដាក់ជូនអង្គជំនុំជម្រះពិនិត្យ និងវាយតម្លៃថាតើសំណងទាំងអស់នោះអាចយកមកអនុវត្តបាន និងមានប្រសិទ្ធិភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ ។

នៅក្នុងការចាប់ផ្តើមនៃដំណើរការនីតិវិធីនៅក្នុងសវនាការ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វុត ត្រូវបានផ្តល់ឱកាសឲ្យឡើងថ្លែងពីសំណើសុំរបស់ខ្លួនទៅអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការកំណត់នូវសំណងជាក់លាក់ ។ ប៉ុន្តែលោកស្រីមេធាវីនាំមុខអន្តរជាតិបានប្រគល់ភារកិច្ចទៅលោកស្រី ម៉ាទីន ហ្សាកាំង មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបង្ហាញពីការយល់ឃើញរបស់ខ្លួនទាក់ទងនឹងការកំណត់នូវសំណងជាក់លាក់ជូនអង្គជំនុំជម្រះ ។ លោកស្រីមេធាវី ម៉ាទីន ហ្សាកាំង បានលើកឡើងអំពីដំណើរការគាក់តែងនៃសំណងដោយសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ឧបសគ្គនៃការអនុវត្តសំណង និងការបំបែកដំណើរការនីតិវិធីដែលនាំឲ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ។ លោកស្រីមេធាវីបានបន្តថា សំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ គឺដូចគ្នាទៅនឹងសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ដែរ ហើយសំណុំរឿង០០១នេះកំពុងរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ។ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលមិនទាន់សម្រេចពីពិរុទ្ធភាពរបស់ជនជាប់ចោទនិងសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកជាខ្លាំងក្នុងការពិចារណាទៅលើការកំណត់ពីភាពជាក់លាក់នៃសំណងដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យធ្វើនៅក្នុងសំណុំរឿង ០០២ ។ លោកស្រីមេធាវី ហ្សាកាំង បានកត់សម្គាល់ថា នៅក្នុងសំណុំរឿង០០១ ទាក់ទងនឹងជនជាប់ចោទ ឌុច អង្គជំនុំជម្រះសាលាដំបូងហាក់បីដូចជាមានការបកស្រាយមួយដែលមានលក្ខណៈចង្អៀត ចំពោះការផ្តល់សំណងដោយបានប្រើប្រាស់បទដ្ឋានមួយខ្ពស់ហួសហេតុដែលជាការរំលោភទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ នៅពេលលើកឡើងពាក់ព័ន្ធនឹងដីកាបំបែកសំណុំរឿង លោកស្រីមេធាវីត្រូវបានអង្គជំនុំជម្រះបញ្ឈប់មិនឲ្យលើកឡើងដោយផ្តល់ហេតុផលថាការលើកឡើងនេះប្រាសចាកទៅនឹងរបៀបវារៈរបស់អង្គជំនុំជម្រះដែលបានកំណត់រួចមកហើយ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតគឺលោក សំ សុគង់ បានលើកឡើងពីការធ្វើបច្ចុប្បន្នភាពនៃសំណង ។ លោកមេធាវី សំ សុគង់ បានកត់សម្គាល់ថាភារកិច្ចដែលអង្គជំនុំជម្រះសាលាដំបូងផ្តល់ឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះគឺជាភារកិច្ចដ៏ច្រើនលើសលប់ដែលមិនធ្លាប់មាននៅក្នុងតុលាការអន្តរជាតិនានា ។ លោក មេធាវី សុគង់ បានបន្តថា ចំពោះនិយមន័យនៃពាក្យជាក់លាក់គ្រប់គ្រាន់ បើមិនទាន់មានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងសំណុំរឿង០០១ទេ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចកំណត់ពីភាពជាក់លាក់នៃសំណងដែលអង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យបង្ហាញបានឡើយ ។ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានកំណត់ពីអត្ថន័យនៃពាក្យជាក់លាក់នោះឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មិនទាន់បានផ្តល់អត្ថន័យច្បាស់លាស់ណាមួយទាក់ទងនឹងពាក្យ“ជាក់លាក់”នេះដែរ រួមទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិផង ។ លោកមេធាវី សុគង់ បានបញ្ជាក់ថា សំណងដែលមានចែង

---

[២] អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា “ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន២៣ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង” ឯកសារ E125 ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ។

នៅក្នុងអនុស្សរណៈចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១របស់អង្គជំនុំជម្រះសាលាដំបូងនៅត្រង់ចំណុចដែលលើកឡើងអំពីវិធានការមួយចំនួនដែលស្ថិតនៅក្រោមវិសាលភាពនៃក្របខ័ណ្ឌគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពាក់ព័ន្ធនឹងការកំណត់សំណងសម្រាប់ជនរងគ្រោះ វាគឺជាការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលចែងថា សំណងត្រូវតែសមាមាត្រទៅនឹងការខូចខាតដែលជនរងគ្រោះទទួលរង ហើយការលើកឡើងនេះក៏ជាការរំលោភទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

នៅមុនពេលនៃការបញ្ចប់ការលើកឡើងរបស់លោកមេធាវី សុគង់ ជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ដោយសារហេតុផលសុខភាព ។ នៅក្នុងសវនាការស្ដីពីការកំណត់នូវសំណងជាក់លាក់នៅព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ គឺមានតែវត្តមានរបស់ជនជាប់ចោទ នួន ជា ម្នាក់គត់ដែលបានចូលរួមស្ដាប់កិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការ ។

## ២) គម្រោងសំណងសំខាន់ៗដែលអាចសម្រេចបាន

សហមេធាវីនាំមុខជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីគឺ លោក ពេជ អង្គ បានផ្ដើបទបង្ហាញពីប្រភេទនៃសំណងដែលជាសំណើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំង៣៨៦៧នាក់ នៅក្នុងសំណុំរឿង០០២ ។ នៅក្នុងសេចក្ដីថ្លែងរបស់ខ្លួនលោកសហមេធាវីនាំមុខ ពេជ អង្គ បានបង្ហាញពីគម្រោងជាក់លាក់ដែលមានលទ្ធភាពអនុវត្តបានដោយបែងចែកជាបួនជំពូកសំខាន់គឺ ទី១) គម្រោងរំឭកចងចាំ ទី២) គម្រោងស្ដារនីតិសម្បទា ទី៣) គម្រោងចងក្រងឯកសារ និងការអប់រំ និងទី៤) គម្រោងសំណងផ្សេងៗ ។

**គម្រោងរំឭកចងចាំ ៖** លោក ពេជ អង្គ លើកឡើងពីគម្រោងរំឭកការចងចាំថា ជាគម្រោងដែលត្រូវបានប្រមូលបញ្ចូលគ្នានូវសំណើចំនួន២៧ ដោយបែកចេញជាគម្រោងតូចៗមួយចំនួនទៀត ដូចជា គម្រោងតស៊ូមតិដើម្បីឲ្យមានថ្ងៃរំឭកចងចាំជាតិ គម្រោងសាងសង់ចេតិយ៍ឬស្តូបរំឭកវិញ្ញាណក្ខន្ធ គម្រោងដែលធ្វើបុណ្យនៅក្រោយពេលសាលក្រមចូលជាស្ថាពរ និងគម្រោងចូលរួមក្នុងការថែរក្សាទីតាំងឧក្រិដ្ឋកម្ម ។

**គម្រោងស្ដារនីតិសម្បទាឡើងវិញ ៖** លោក ពេជ អង្គ លើកឡើងថា គម្រោងស្ដារនីតិសម្បទាឡើងវិញ បែកចេញជាគម្រោងតូចៗទៀត ដូចជាគម្រោងបង្កើតជាសេវាព្យាបាលជំងឺផ្លូវចិត្ត និង



សហមេធាវីនាំមុខអន្តរជាតិ និងជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វុត និង លោក ពេជ អង្គ (រូបថត ៖ អ.វ.ត.ក)

សុខភាពរូបកាយគម្រោងជួយគ្នាទៅវិញទៅមកដើម្បីធ្វើឲ្យមានការផ្សះផ្សា ។

**គម្រោងចងក្រងឯកសារ និងការអប់រំ** ៖ លោក ពេជ អង្គ លើកឡើងបន្តថា គម្រោងចងក្រងឯកសារ និងការអប់រំនេះ រួមបញ្ចូលជាគម្រោងតូចៗជាច្រើនទៀតដូចជា

◆ គម្រោងបង្កើតឲ្យមានកម្មវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងចែកចាយឯកសារ ដែលអាចជួយធ្វើឲ្យមានការចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

◆ គម្រោងគស្ស៊ូមតិដើម្បីធ្វើឲ្យមានមជ្ឈមណ្ឌលឯកសារ បណ្ណាល័យ សារមន្ទីរ ដើម្បីថែរក្សាឯកសារ និងរបស់របរដើម្បីអាចឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រជាជនកម្ពុជាទទួលបានជាប្រយោជន៍ ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គភាពគាំពារជនរងគ្រោះ ។

◆ បង្កើតឲ្យមានបញ្ជីចុះឈ្មោះជនរងគ្រោះ ឬក្រាំងមាស ។

◆ គម្រោងចុះឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីចូលទៅក្នុងសាលក្រម ។

◆ គម្រោងបង្កើតមជ្ឈមណ្ឌលដួងព្រលឹងនៃប្រជាជនកម្ពុជា និង

◆ គម្រោងបង្កើតមជ្ឈមណ្ឌលសម្រាប់អភិរក្សវប្បធម៌របស់ជនជាតិចាមដើម្បីធ្វើឲ្យមានការរួបរួមពូជសាសន៍ឡើងវិញ ។

**គម្រោងសំណងផ្សេងៗ**

លោកស្រីមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វត លើកឡើងទាក់ទងនឹងការបង្កើតមូលនិធិសំណងឯករាជ្យមួយដើម្បីសម្រេចគម្រោងសំណងទាំងឡាយឲ្យបាន ហើយជនរងគ្រោះទាំងអស់នឹងអាចទទួលបានប្រយោជន៍ពីគម្រោងនេះ ។ លោកស្រីមេធាវីបន្តថា ត្រូវបង្កើតអង្គការសម្រាប់ត្រួតពិនិត្យការអនុវត្តសំណង ដោយផ្តល់ព័ត៌មានទាំងឡាយទាក់ទងនឹងសំណងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងអ្នកពាក់ព័ន្ធទាំងអស់ ។ បន្ថែមលើសពីនេះ គឺត្រូវសម្របសម្រួលផ្តល់សញ្ជាតិខ្មែរជូនជនរងគ្រោះដែលជាជនជាតិវៀតណាមថែមទៀត ។ លោកស្រីយល់ថា ត្រូវបង្កើតគម្រោងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដែលអនុញ្ញាតឲ្យកូនៗរបស់ជនរងគ្រោះអាចទទួលបានអាហារូបករណ៍ចូលរៀនដោយមិនចាំបាច់បង់ថ្លៃនិងអាចស្វែងរកការងារសម្រាប់អ្នកទាំងនោះក្រោយពេលបញ្ចប់ការសិក្សា ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ការស្នើសុំសំណងនេះកំពុងស្ថិតនៅក្នុងដំណាក់កាលពិភាក្សាគ្នានៅឡើយ ចាំបាច់ត្រូវមានការជជែកពិភាក្សាគ្នាច្រើនបន្ថែមទៀតដើម្បីដោះស្រាយបញ្ហាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលរងការបាត់បង់ការឈឺចាប់ ដោយសាររបបខ្មែរក្រហម ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកអង្គជំនុំជម្រះសាលាដំបូងថា អង្គជំនុំជម្រះមិនគួរធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីខកចិត្តដោយសារតែបញ្ហាសំណងឡើយ

***១) សហព្រះរាជអាជ្ញា ៖ អង្គជំនុំជម្រះត្រូវផ្តល់សំណងដោយយោងទៅលើច្បាប់***

ក្រោយពីបញ្ចប់ការបង្ហាញទាក់ទងទៅនឹងគម្រោងសំណងជាក់លាក់របស់សហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាឡើងថ្លែងពីមតិយល់ឃើញរបស់ខ្លួនពាក់ព័ន្ធនឹងការកំណត់ភាពជាក់លាក់នៃសំណង ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឹកចិត្តឲ្យអង្គជំនុំជម្រះផ្តល់សំណងដែលមានខ្លឹមសារដល់ជនរងគ្រោះដោយសំណងនោះគួរតែសមាមាត្រទៅនឹងអ្វីដែលបានបាត់បង់នៅសម័យខ្មែរក្រហម ។ ចំណែកឯសហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង បានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលទៅលើច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅត្រង់មាត្រា៣៦ថ្មី[៣] មាត្រា២ វាក្យខ័ណ្ឌ២ មាត្រា១៤ និងមាត្រា៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[៤] មាត្រា១៤នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ វិធាន២៣ស្ទួនបួន និងវិធាន១១៣

[៣] ចែងអំពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី ។

នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៥] ម្យ៉ាងវិញទៀត សាលក្រមដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ មិនបានបង្ហាញពីនីតិវិធីក្នុងការស្នើសុំសំណងឲ្យបានច្បាស់លាស់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ ការផ្តល់សំណងរដ្ឋប្បវេណីទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់អង្គជំនុំជម្រះ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ។ បើមិនមានការផ្តល់សំណងទៅឲ្យជនរងគ្រោះទេ ការចូលរួមរបស់ជនរងគ្រោះនឹងក្លាយទៅជារឿងគ្មានន័យទាល់តែសោះ ។

### ក) មេធាវីការពារក្តី ៖ សំណើសុំសំណងត្រូវតែមានភាពច្បាស់លាស់

ឆ្លើយតបទៅនឹងការស្នើសុំសំណងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ស៊ុន អារុណ សហមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា បានលើកឡើងថា ខ្លួនយល់ស្របនឹងការស្នើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែតម្រូវឲ្យសហមេធាវីនាំមុខត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ពីព្យសនកម្មដែលជនរងគ្រោះបានទទួលរងជាមុនសិន ទើបគេអាចចេញសងសំណងការខូចខាត ទៅឲ្យជនរងគ្រោះបាន ។ រីឯតួលេខដែលថាមានការស្លាប់បាត់បង់ជីវិតចំនួន១,៧លាននាក់នោះ លោកមេធាវី ស៊ុន អារុណ អះអាងថា មិនដឹងថាតើតួលេខនោះបានមកពីប្រភពណាមួយឡើយ ។ ទាក់ទងទៅនឹងការលើកឡើងពីការស្លាប់បាត់បង់ជីវិតរបស់ជនជាតិភាគតិចដែលមានជនជាតិចាម និងជនជាតិវៀតណាម លោកមេធាវី ស៊ុន អារុណ បានស្នើឲ្យសហមេធាវីនាំមុខត្រូវពិចារណាឲ្យបានច្បាស់ជាមុន ពីព្រោះថា ជនជាតិចាមក៏ជាជាតិខ្មែរដូចជាប្រជាជនទូទៅដែរ រីឯជនជាតិវៀតណាមវិញ ត្រូវបែងចែកឲ្យបានច្បាស់ថា ជាជនអន្តោប្រវេសន៍ស្របច្បាប់ ឬខុសច្បាប់ ។

ចំណែកឯ លោកមេធាវី ផាត់ ពៅស៊ាង សហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ទទួលស្គាល់ថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យពិតជាមានការកាប់សម្លាប់ទៅលើជនជាតិចាម និងវៀតណាម ក៏ប៉ុន្តែសុំឲ្យសហមេធាវីនាំមុខកុំបែងចែកថា ជាជនជាតិចាម ឬវៀតណាម ព្រោះអ្នកដែលស្លាប់គឺសុទ្ធតែជាមនុស្ស ។ ដូច្នេះគេត្រូវទាមទារសំណងសម្រាប់មនុស្សទាំងឡាយដែលបានបាត់បង់ជីវិតដោយសារខ្មែរក្រហម ។

លោក ម៉ៃឃើល ខណាវ៉ាស សហមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានគាំទ្រចំពោះសំណើសុំដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូនទៅអង្គជំនុំជម្រះ និងថានេះគឺជាអ្វីដែលរដ្ឋាភិបាលគួរតែធ្វើ ។ លោកស្នើសុំឲ្យតុលាការបង្កាប់ឲ្យមានជាសំណើណាមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែលទ្ធភាពធ្វើយ៉ាងណានោះ គឺទុកឲ្យអង្គជំនុំជម្រះសាលាដំបូង និងច្បាប់ជាអ្នកអនុវត្តន៍ ។ សម្រាប់លោក អាង ឧត្តម សហមេធាវីជាតិរបស់ជនជាប់ចោទ អៀង សារី បានស្នើសុំឲ្យតុលាការមេត្តាពិចារណាឲ្យបានលម្អិតទាក់ទងនឹងការផ្តល់សញ្ជាតិទៅឲ្យជនជាតិវៀតណាម ពីព្រោះថានៅសម័យនោះមិនដឹងថាច្បាប់ចែងបែបណានោះទេ ហើយជនជាតិវៀតណាមដែលទទួលបានសញ្ជាតិនោះ ថាតើកូនៗរបស់ពួកគេដែលកើតមកនឹងទទួលបានសញ្ជាតិខ្មែរដែរឬយ៉ាងណា ។ លោកបន្តថា បើយោងតាមច្បាប់ស្តីពីសញ្ជាតិ នៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ ការផ្តល់សញ្ជាតិអាចធ្វើទៅបានដោយយោងទៅកត្តាបួនយ៉ាង ៖

១) ការផ្តល់សញ្ជាតិអាចធ្វើទៅបានចំពោះជនបរទេសដែលបានកើតនៅស្រុកខ្មែរ ។

២) ជនបរទេសត្រូវបានផ្តល់សញ្ជាតិខ្មែរ តាមរយៈការរៀបអាពាហ៍ពិពាហ៍ ។

៣) ផ្តល់សញ្ជាតិខ្មែរឲ្យដល់វិនិយោគិនដែលបានវិនិយោគនៅក្នុងប្រទេសកម្ពុជាក្នុងចំនួនទឹកប្រាក់ណាមួយដែលរដ្ឋាភិបាលតម្រូវ ។

៤) អំណោយដែលផ្តល់ឲ្យរដ្ឋាភិបាលក្នុងចំនួនណាមួយ ។

---

[៤] ពាក់ព័ន្ធទៅនឹងការទទួលបានសំណងការខូចខាតរបស់ជនរងគ្រោះនូវអ្វីដែលខ្លួនបានបាត់បង់ ។

[៥] ចែងអំពីសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងសិទ្ធិរបស់ជនរងគ្រោះដើម្បីទទួលបានសំណង ។

លោកអះអាងថា ការស្នើសុំឲ្យមានការសម្របសម្រួលក្នុងការផ្តល់សញ្ជាតិទៅដល់ជនរងគ្រោះដែលជាជនជាតិវៀតណាមនោះមិនមានចែងនៅក្នុងច្បាប់ស្តីពីសញ្ជាតិរបស់កម្ពុជានាពេលបច្ចុប្បន្ននេះឡើយ ។

**២) សវនាការស្តីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ**

នៅក្រោយពេលការនៃបញ្ចប់សវនាការទាក់ទងនឹងការកំណត់ជាក់លាក់នូវសំណង សវនាការដាច់ដោយឡែកមួយទៀតពាក់ព័ន្ធនឹងការសួរដេញដោលទៅលើអ្នកជំនាញផ្នែកវិកលវិទ្យាទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានចាប់ផ្តើមនាពេលរសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ។

***ក) ការវាយតម្លៃចំពោះសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ***

នៅក្នុងសវនាការ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោលទៅលើអ្នកជំនាញស្តីអំពីកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីវាយតម្លៃថាតើការចុះខ្សោយសតិបញ្ញានិងការចងចាំរបស់ជនជាប់ចោទរូបនេះមានការចុះខ្សោយក្នុងកម្រិតណាមួយ ។

នៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង[6] អង្គជំនុំជម្រះបានផ្តល់នូវសំណួរចំនួនប្រាំទៅដល់ភាគីទាំងអស់ដើម្បីធ្វើការឆ្លើយតប បន្ទាប់ពីការពិនិត្យទៅលើរបាយការណ៍របស់អ្នកជំនាញថ្មីទាំងបួនរូប ។ សំណួរទាំងនោះរួមមាន៖

១) តើជនជាប់ចោទមួយរូបអាចត្រូវបានចាត់ទុកថាពុំមានកាយសម្បទា បញ្ញា ស្មារតីផ្នែកបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ ដោយគ្រាន់តែរកឃើញថា លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យនានាដូចដែលបានបង្ហាញនៅសំណុំរឿង ស្ទ្រូហ្គា ត្រូវបានបំពេញនោះ ឬមួយក៏ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងអស់រួមបញ្ចូលគ្នានៅពេលធ្វើការវាយតម្លៃកាយសម្បទា បញ្ញា ស្មារតីជនជាប់ចោទ?

២) តើការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកប្រព័ន្ធប្រសាទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលសាស្ត្រាចារ្យ ខាំប៊ែល និងអ្នកជំនាញវិកលវិទ្យាបានរកឃើញធ្វើឲ្យជនជាប់ចោទរូបនេះគ្មានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ស្របតាមបទដ្ឋានតម្រូវចាំបាច់នៅក្នុងសំណុំរឿងស្ទ្រូហ្គា មែនឬទេ?

៣) តើកម្រិតនៃការធ្លាក់ចុះខ្សោយធ្ងន់ធ្ងរផ្នែកសមត្ថភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការឆ្លើយសំណួរ ណែនាំមេធាវីផ្តល់សក្ខីកម្ម យល់ពីប្រភេទនៃបទចោទ និងដំណើរការនីតិវិធី


អៀង សារី (ឆ្វេង) និង អៀង ធីរិទ្ធ (ស្តាំ) (រូបថត ៖ អ.វ.ត.ក)

យល់លម្អិតពីភស្តុតាង និងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី បញ្ជាក់ថាជនជាប់ចោទរូបនេះពុំមានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដែរឬទេ ដោយពិចារណាទៅលើកត្តាដែលថាជនជាប់ចោទមានមេធាវីតំណាង និងអាចអនុវត្តសិទ្ធិទាំងអស់នេះបានមួយផ្នែកតាមរយៈមេធាវីរបស់ខ្លួននោះ?

៤) ដូចដែលអ្នកជំនាញទាំងអស់បានរកឃើញថាស្ថានភាព

---

[6] ដីកាកំណត់កាលបរិច្ឆេទសវនាការដែលនឹងត្រូវធ្វើនៅថ្ងៃទី១៩-២០ ខែតុលា ឆ្នាំ២០១១ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ឯកសារលេខ E129 ។

របស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺកាន់តែទ្រុឌទ្រោមទៅៗ និងអាចពន្យារពេលកិច្ចដំណើរការនីតិវិធីមិនឈប់ឈរ ដូចជាត្រូវពិនិត្យបន្ថែម ឬជាប្រចាំថ្ងៃ ឬស្ថានភាពប្រចាំថ្ងៃរបស់គាត់មិននឹងនរជាដើម ។ ដោយសារកត្តាទាំងអស់នេះអាចប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទផ្សេងទៀតក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស និងអូសបន្លាយកិច្ចដំណើរការនីតិវិធីលើសំណុំរឿងលេខ០០២ទាំងមូល តើភាគីយល់ឃើញថា ជាផលប្រយោជន៍នៃ



យុត្តិធម៌ដែរឬទេ ដែលត្រូវបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីដំណើរការនីតិវិធីទាំងនេះ ដោយអនុលោមតាមវិធាន ៨៩ស្ទួនពីរ (ដូចជាជម្រើសដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលជនជាប់ចោទត្រូវបានរកឃើញថាពុំមានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ) ?

៥) តើបច្ច័យអ្វីខ្លះចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ដែលអាចកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមវិធាននេះ?

ខណៈពេលដែលភាគីនីមួយៗធ្វើសេចក្តីសន្និដ្ឋានដើម្បីឆ្លើយតបទៅនឹងសំណួរទាំងប្រាំរបស់អង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ថារីក អាប់ឌុល បានលើកឡើងថាសហព្រះរាជអាជ្ញាគោរពចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានលើកឡើងថា យោងតាមការលើកឡើងរបស់អ្នកជំនាញ ជនជាប់ចោទ អៀង ធីរិទ្ធ គឺមានលទ្ធភាពចូលរួមសវនាការក្នុងចំណោមលទ្ធភាពទាំងប្រាំចំណុច ដែលមានដូចជាការឆ្លើយតបទៅនឹងបទចោទយល់អំពីលក្ខណៈនៃបទចោទ យល់អំពីព័ត៌មានលម្អិតនៃភស្តុតាង និងយល់អំពីផលវិបាកនៃនីតិវិធី និងការផ្តល់សក្ខីកម្ម ។ ទាំងអស់នេះជាកាយសម្បទា បញ្ញា ស្មារតី ដែលចៅក្រមបានកំណត់ក្នុងការស្វែងយល់ពីលទ្ធភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមក្នុងសវនាការ ។ អ្នកជំនាញ លីនណា និង ហ្វាហ្វែល លើកឡើងថា ជនជាប់ចោទ អៀង ធីរិទ្ធ មានការសប្បាយរីករាយក្នុងការផ្តល់សម្ភាសន៍ជូនអ្នកជំនាញ ហើយអាចធ្វើសម្ភាសន៍បានដោយប្រើរយៈពេលយូរថែមទៀតផង ។ ម្យ៉ាងវិញទៀត ជនជាប់ចោទ អៀង ធីរិទ្ធ អាចនិយាយបានដល់ទៅពីរភាសាយ៉ាងស្ទាត់ជំនាញ ។ នេះបង្ហាញឲ្យឃើញថា ជនជាប់ចោទរូបនេះនៅមានស្មារតីចងចាំមួយដែលអាចទទួលយកបាន ។

សម្រាប់សហមេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺលោកស្រី ដាយអាណា អេលីស បានអះអាងថាកូនក្តីរបស់ខ្លួនមានជំងឺវង្វេងវង្វាន់ដែលមិនអាចចងចាំបាននូវព្រឹត្តិការណ៍បុគ្គលដែលពាក់ព័ន្ធ និងតួនាទីរបស់ខ្លួន ឬបុគ្គលណាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ នេះជាហេតុនាំឲ្យជនជាប់ចោទ អៀង ធីរិទ្ធ មិនអាចធ្វើសក្ខីកម្ម ឬការជំទាស់ទៅនឹងសក្ខីកម្មណាមួយដែលធ្វើដោយសាក្សីនៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តីនាពេលខាងមុខ ព្រមទាំងមិនអាចធ្វើការណែនាំទៅដល់មេធាវីរបស់ខ្លួនបានឡើយ ។ ហេតុនេះជនជាប់ចោទ អៀង ធីរិទ្ធ នឹងមិនអាចអនុវត្តនូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌បានទេ ប្រសិនបើជនជាប់ចោទរូបនេះ ត្រូវចូលរួមសវនាការនៅពេលឆាប់ៗខាងមុខ ។ លោកស្រីមេធាវីអន្តរជាតិ ដាយ

អាណា អេលីស បានលើកជាយោបល់ថា ប្រសិនបើជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានតុលាការរកឃើញថាមានកាយសម្បទាបញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ អង្គជំនុំជម្រះគួរតែបើកសវនាការមួយដាច់ដោយឡែកពីជនជាប់ចោទដទៃទៀត ដើម្បីជំនុំជម្រះលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយសារតែជនជាប់ចោទរូបនេះត្រូវការជំនួយពីសំណាក់មេធាវី និងការព្យាបាលច្រើន ។ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការទេនោះ តុលាការអាចបន្តឃុំខ្លួនកូនក្តីរបស់ខ្លួនបន្តទៀត ឬអាចធ្វើឲ្យជនជាប់ចោទមានលក្ខណៈប្រសើរជាងនេះ ដោយឲ្យអនុញ្ញាតឲ្យជនជាប់ចោទ អៀង ធីរិទ្ធ នៅក្រៅឃុំបណ្តោះអាសន្នមួយរយៈដើម្បីឲ្យស្ថានភាពសុខភាពប្រសើរជាងមុន ។

ចំពោះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការគាំទ្រជាមួយនឹងសហព្រះរាជអាជ្ញា ដែលថាជនជាប់ចោទរូបនេះមានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមនីតិវិធីរួចទៅហើយ ដូចដែលអ្នកជំនាញ វិកលវិទ្យាទាំងពីររូបបានលើកឡើងថា ជនជាប់ចោទ អៀង ធីរិទ្ធ បានធ្វើការជំទាស់ទៅនឹងពិរុទ្ធភាពរបស់ខ្លួន ដោយនិយាយថាខ្លួនមិនបានសម្លាប់មនុស្សជាដើម ។ នេះបង្ហាញឲ្យឃើញថា ជនជាប់ចោទរូបនេះមិនមែនអសមត្ថភាពនោះទេ ប៉ុន្តែការបដិសេធនឹងការរកឃើញពីពិរុទ្ធភាពរបស់ខ្លួននោះ បានបង្ហាញយ៉ាងច្បាស់ពីឆន្ទៈរបស់ជនជាប់ចោទក្នុងការមិនចង់ចូលរួមសវនាការ ។

តាមរបាយការណ៍ និងការសួរដេញដោលនៅក្នុងសវនាការពីរថ្ងៃអ្នកជំនាញផ្នែកវិកលវិទ្យាពីររូប គឺលោកវេជ្ជបណ្ឌិត ហួត លីនណា និងលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល បានសន្និដ្ឋានថាជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីធ្ងន់ធ្ងរកម្រិតមធ្យម ។ នៅក្នុងសវនាការអង្គជំនុំជម្រះបានសួរសំណួរមួយចំនួនទាក់ទងនឹងកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទទៅកាន់អ្នកជំនាញទាំងពីរនាក់ ដូចមានចែងនៅក្នុងមាត្រា៣៩ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រានេះកំណត់អំពីកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងអាចអនុវត្តសិទ្ធិទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ដើម្បីទទួលបានការអនុវត្តសិទ្ធិក្នុងការចូលរួមសវនាការប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ ជនជាប់ចោទត្រូវតែមានសមត្ថភាពយ៉ាងហោចណាស់ ១) អាចជជែកតតាំងដើម្បីការពារខ្លួននៅក្នុងសវនាការ ២) អាចយល់ដឹងពីលក្ខណៈនៃបទល្មើសដែលគេចោទមកលើខ្លួន ៣) អាចយល់ដឹងពីកិច្ចដំណើរការនីតិវិធី ៤) អាចយល់ដឹងពីផលវិបាកនិងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី ៥) អាចយល់ដឹងពីភាពលម្អិតនៃភស្តុតាងដោះបន្ទុកនិងដាក់បន្ទុក ៦) អាចពន្យល់ប្រាប់មេធាវីរបស់ខ្លួនពីអង្គហេតុនិងភស្តុតាងដែលអាចមាន ៧) ជនជាប់អាចផ្តល់សក្ខីកម្មបាន ។

**១) អ្នកជំនាញ ៖ អៀង ធីរិទ្ធ មានការលំបាកក្នុងការតាមដាននីតិវិធីតុលាការ**

នៅពេលចាប់ផ្តើមដំបូងនៃសវនាការស្តីពីកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ចៅក្រមអន្តរជាតិ លោកស្រីស៊ីលវៀ ខាតវ៉ាយត៍ បានសួរសំណួរមួយចំនួនទៅអ្នកជំនាញផ្នែកវិកលវិទ្យា ក្នុងការស្វែងយល់អំពីកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ បន្ទាប់ពីការសួរអំពីប្រវត្តិសិក្សា ការងារ និងបទពិសោធន៍របស់អ្នកជំនាញផ្នែកវិកលវិទ្យាគឺ លោកវេជ្ជបណ្ឌិត ហួត លីនណា និងលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាហ្សែល រួចមក លោកស្រី ចៅក្រម ខាតវ៉ាយត៍ បានសួរអំពីការវិនិច្ឆ័យ រោគរបស់អ្នកជំនាញទៅលើជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីឲ្យមានការពន្យល់ទៅលើរបាយការណ៍កោសល្យវិច័យ ។ អ្នកជំនាញទាំងពីររូបបានពន្យល់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវិកលចរិត ដោយកំពុងស្ថិតនៅក្នុងស្ថានភាពធ្លាក់ចុះនៃការចងចាំ ។ លោកទាំងពីរបានបន្តទៀតថា ការធ្លាក់ចុះនៃសមត្ថភាពសតិបញ្ញាដែលពាក់ព័ន្ធនឹងការវិនិច្ឆ័យ និងការគិតគូរ ការយល់ដឹងពីបរិយាកាសជុំវិញខ្លួន ការធ្លាក់ចុះនៃសមត្ថភាពគ្រប់គ្រងអារម្មណ៍ ឬការធ្វើឲ្យបាត់បង់នូវឥរិយាបថសង្គម និងការធ្លាក់ចុះនៃការចងចាំរបស់ជនជាប់ចោទរូបនេះកើតឡើងប្រហែលជាមួយឆ្នាំមកហើយ ។

លោកស្រីចៅក្រម ខាតវ៉ាយត៍ ក៏បានសួរទៅអ្នកជំនាញទាក់ទងទៅនឹងសមត្ថភាពយល់ដឹងពីបទចោទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម

ខាតព្រ៉ាយត៍ អ្នកជំនាញទាំងពីររូបបានពន្យល់ថា វាមានការលំបាកក្នុងការធ្វើការវិនិច្ឆ័យទៅលើសមត្ថភាពយល់ដឹងអំពីបទចោទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដោយសារជនជាប់ចោទរូបនេះមិនបានព្យាយាមបង្ហាញ ប៉ុន្តែមានពេលមួយនោះ ជនជាប់ចោទ អៀង ធីរិទ្ធ បានលើកឡើងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថា ប្រជាជនទាំងមូលត្រូវបានបាត់ខ្លួន ។ ចំពោះសំណួរអំពីបទល្មើសមនុស្សឃាតវិញ ជនជាប់ចោទរូបនេះឆ្លើយថា ខ្លួនមិនធ្លាប់បានសម្លាប់នរណាម្នាក់ទេ និងបានលើកឡើងថាជាអំពើដែលមនុស្សម្នាក់សម្លាប់មនុស្សម្នាក់ទៀត ។ នៅពេលដែលសួរថា អ្វីទៅជាអំពើប្រល័យពូជសាសន៍ ជនជាប់ចោទ អៀង ធីរិទ្ធ បានលើកឡើងអំពីប្រជាជនទាំងមូល ។ ទាក់ទងទៅនឹងពាក្យទារុណកម្ម ជនជាប់ចោទ អៀង ធីរិទ្ធ ឆ្លើយថាមិនមាននរណាម្នាក់ជួបគ្រោះថ្នាក់ដូច្នោះទេ ។ នៅពេលលើកឡើងពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ជនជាប់ចោទ ឆ្លើយដោយស្រពិចស្រពិលថា ប្រជាជនកម្ពុជាមិនមានមហិច្ឆតាដូច្នោះនោះទេ ។ អ្នកជំនាញទាំងពីររូបបានបន្តទៀតថាជនជាប់ចោទ អៀង ធីរិទ្ធ មានលទ្ធភាពអាចយល់ដឹងពីបទចោទ ។ ទាក់ទងទៅនឹងលទ្ធភាព យល់ដឹងទៅលើនីតិវិធីរបស់តុលាការ អ្នកជំនាញ ស៊ីណា ហ្វាហ្សែល បានលើកឡើងយ៉ាងច្បាស់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនអាចយល់ដឹងលម្អិតអំពីកិច្ចដំណើរការនីតិវិធីបានទេ ប៉ុន្តែជនជាប់ចោទរូបនេះអាចដឹងពីកិច្ចដំណើរការនីតិវិធីទូទៅដែលប៉ះពាល់ទៅលើខ្លួន ។ អៀង ធីរិទ្ធ មានការលំបាកខ្លាំងចំពោះការយល់អំពីកិច្ចដំណើរការនីតិវិធី ជាពិសេសគឺជនជាប់ចោទមិនយល់អំពីដំណើរការនីតិវិធីតទល់មុខគ្នានោះទេ បើទោះជាអ្នកជំនាញរូបនេះព្យាយាមពន្យល់យ៉ាងណាក៏ដោយ ។ វេជ្ជបណ្ឌិត ហ្វាហ្សែល ជឿជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ មិនអាចរក្សាព័ត៌មានបានយូរនោះទេ ជនជាប់ចោទមានការលំបាកខ្លាំងក្នុងការស្វែងយល់ចំពោះកិច្ចដំណើរការនីតិវិធីតុលាការ ជាពិសេសការលើកឡើងតាមរយៈការផ្តល់សក្ខីកម្មរបស់សាក្សី និងមេធាវី ។ អ្នកជំនាញរូបនេះបានបន្តទៀតថា ជនជាប់ចោទមានលទ្ធភាពក្នុងការសហការជាមួយមេធាវី ប៉ុន្តែមានការលំបាកក្នុងការជួយជ្រោមជ្រែងមេធាវីដើម្បីធ្វើការការពារក្តីឲ្យខ្លួន ។ នៅពេលដែលលោកស្រីចៅក្រម ខាតព្រ៉ាយត៍ ចោទសួរអ្នកជំនាញទាំងពីររូបថា តើជនជាប់ចោទ អៀង ធីរិទ្ធ មានលទ្ធភាពក្នុងការផ្តល់សក្ខីកម្មនៅក្នុងអង្គសវនាការឬទេ? អ្នកជំនាញទាំងពីររូបបានពន្យល់ថា ជនជាប់ចោទអាចមានលទ្ធភាពយល់អំពីសំណួរដែលសួរទៅកាន់ខ្លួន និងអាចឆ្លើយតបទៅនឹងសំណួរទាំងនោះបាន ថែមទាំងមានលទ្ធភាពធ្វើសក្ខីកម្ម បើទោះជាចម្លើយនោះមិនអាចជឿជាក់បានក៏ដោយ ហើយជនជាប់ចោទនៅតែមានលទ្ធភាពឆ្លើយសំណួរ និងអាចការពារខ្លួនបាន ។ ពាក់ព័ន្ធទៅនឹងលទ្ធភាពយល់ដឹងពីផលវិបាកនៃការកាត់ទោសមកលើខ្លួនរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អ្នកជំនាញយល់ថា ថ្វីត្បិតតែជនជាប់ចោទព្យាយាមមិនឆ្លើយនឹងសំណួរទាក់ទងនឹងផលវិបាកដែលកើតចេញពីការកាត់ទោសមកលើខ្លួនក៏ដោយ ក៏ជនជាប់ចោទយល់ពីផលវិបាកក្នុងការរកឃើញថាខ្លួនឆ្កួត ហើយនៅពេលដែលបង្ហាញរូបថត និងអត្ថបទមួយដែលនិយាយពីបញ្ហាកាយសម្បទា បញ្ញា ស្មារតី ជនជាប់ចោទ អៀង ធីរិទ្ធ បានចង្អុលចំពាក្យជំងឺវង្វេងវង្វាន់ *“Dementia”* ហើយនិយាយថា ជនជាប់ចោទអាចឆ្កួតហើយ ដូចនេះមិនមាននរណាអាចមកកាត់ទោសមនុស្សឆ្កួតនោះឡើយ ។ ដូច្នេះ អ្នកជំនាញទាំងពីរនាក់នេះយល់ថាជនជាប់ចោទអាចមានលទ្ធភាពយល់ពីការកាត់ទោសមកលើរូបខ្លួនបាន ។ ជនជាប់ចោទ អៀង ធីរិទ្ធ ក៏មានលទ្ធភាពតាមដានដំណើរការតុលាការតាមមធ្យោបាយសោតទស្សន៍បានដែរ ប្រសិនបើមានមេធាវីម្នាក់ដែលនិយាយភាសាខ្មែរនៅក្បែរ ។ ប៉ុន្តែអ្នកជំនាញទាំងពីររូបនេះក៏បានកត់សម្គាល់ដែរថា ស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អាចនឹងធ្វើឲ្យប៉ះពាល់ទៅដល់ដំណើរការនីតិវិធី ហើយថែមទាំងអាចរារាំង និងបង្អាក់ទៅដល់ដំណើរការសវនាការទៀតផង ដោយសារលក្ខណៈឡើងចុះសមត្ថភាពនៃការចងចាំរបស់ជនជាប់ចោទ ដែលពេលខ្លះអាចត្រូវការពេលវេលា និងព័ត៌មានមួយចំនួនពីក្រុមអ្នកច្បាប់ដើម្បីឲ្យមានការចងចាំឡើងវិញ ។ ចំពោះសំណួរដែរសួរថា តើគួរតែមានការធ្វើកោសល្យវិច័យបន្ថែមជាញឹកញាប់ដែរឬទេ? លោកវេជ្ជបណ្ឌិត ហ្វាហ្សែល បានឆ្លើយថា វាជាប្រយោជន៍ក្នុងការតាមដានស្ថានភាពសតិបញ្ញារបស់ជនជាប់ចោទ ។ ការធ្វើកោសល្យវិច័យបន្ថែមអាចធ្វើបានប៉ុន្មានដងនោះ គឺអាស្រ័យលើស្ថានភាពរបស់ជនជាប់ចោទផ្ទាល់ ប៉ុន្តែវាគួរតែត្រូវបានធ្វើឡើងក្នុងរយៈពេលបីខែម្តង ។

### ក) ការសួរដេញដោលដោយភាគីទៅលើអ្នកជំនាញស្តីពីស្ថានភាពកាយសម្បទា បញ្ញា ស្មារតីរបស់ អៀង ធីរិទ្ធ

#### ១) មេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ

ក្រោយពីការសួរដេញដោលទៅលើអ្នកជំនាញពីសំណាក់លោកស្រីចៅក្រម ខាតព្រ៉ាយត៍ ប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន បានផ្តល់ឱកាសឲ្យភាគីមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ សួរសំណួរមួយចំនួនទៅអ្នកជំនាញ ។ លោកមេធាវី ផាត់ ពៅស៊ាង សហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ បានស្នើសុំឲ្យអ្នកជំនាញទាំងពីររូបធ្វើការបញ្ជាក់បន្ថែមពីសមត្ថភាពយល់ដឹងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ លោកវេជ្ជបណ្ឌិត ហ្វូត លីនណា និងលោកវេជ្ជបណ្ឌិត ហ្សាហ្វែរុល បានបញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានលទ្ធភាពក្នុងការតាមដាននីតិវិធីនៅក្នុងសវនាការនោះទេ ។ ជនជាប់ចោទមានការយល់ដឹងពីការចោទប្រកាន់ និងលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម ប៉ុន្តែជនជាប់ចោទរូបនេះមានការលំបាកខ្លាំងក្នុងការយល់ដឹងពីនីតិវិធី ព្រោះតែការចុះខ្សោយសតិបញ្ញាដែលបណ្តាលមកពីកង្វះសមត្ថភាពក្នុងការរក្សាទុកព័ត៌មានដែលខ្លួនបានស្តាប់នៅក្នុងរយៈពេលវែងមួយ ។ អ្នកជំនាញទាំងពីររូបបានបញ្ជាក់ថា លទ្ធភាពរបស់ជនជាប់ចោទក្នុងការតាមដាននីតិវិធីតុលាការត្រូវបានធ្លាក់ចុះខ្សោយនិងមានការលំបាកក្នុងការតាមដាននីតិវិធីក្នុងសវនាការ ។ លោកស្រីមេធាវី ដាយអាណា អេលីស បានបន្តចោទសួរទៅវេជ្ជបណ្ឌិតទាំងពីររូបដោយបានសួរនូវសំណួរមួយចំនួនទាក់ទងនឹងភាពវង្វេងវង្វាន់ចំពោះសមាជិកគ្រួសារ និងសកម្មភាពមួយចំនួនដែលខុសប្លែកពីសកម្មភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅដែលសំណួរទាំងអស់នោះត្រូវបានយល់ស្របស្មើរតែទាំងស្រុងដោយអ្នកជំនាញ ។ លោកវេជ្ជបណ្ឌិត ហ្សាហ្វែរុល បានញ្ជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ មានការចុះខ្សោយការចងចាំរយៈពេលវែង ។ លោកស្រីមេធាវីអន្តរជាតិបានសួរបញ្ជាក់ទៅលើលោកវេជ្ជបណ្ឌិត ហ្សាហ្វែរុល ទាក់ទងនឹងការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ខាំប៉ែល ដែលថាជនជាប់ចោទ អៀង ធីរិទ្ធ មិនបានធ្វើពុតជាភ្លេចភ្លាំងនោះ លោកវេជ្ជបណ្ឌិត ហ្សាហ្វែរុល បានឆ្លើយតបថាជនជាប់ចោទ អៀង ធីរិទ្ធ មិនបានធ្វើពុតជាភ្លេចភ្លាំងនោះឡើយ ។

#### ២) សហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញារងជាតិគឺលោក ចាន់ តារាវស្មី បានចោទសំណួរមួយចំនួនដល់អ្នកជំនាញទាំងពីរ ។ លោកសហព្រះរាជអាជ្ញាបានសួរថាតើជំងឺវង្វេងវង្វាន់នេះអាចព្យាបាលជាឬទេ? ប្រសិនបើមិនអាចជាដាច់ទេ ហើយប្រសិនបើយើងចង់ព្យាបាលឲ្យនៅកម្រិតទាប តើប្រើរយៈពេលប៉ុន្មានដែរ? លោកវេជ្ជបណ្ឌិត ហ្វូត លីណា បានបញ្ជាក់ថាចំពោះជំងឺវង្វេងវង្វាន់ វាមានជំងឺតូចៗដែលនៅក្នុងនេះច្រើន ហើយមានជំងឺតូចៗខ្លះអាចព្យាបាលឲ្យជាដាច់បាន ។ លោកសហព្រះរាជអាជ្ញារង ចាន់ តារាវស្មី បានបន្តសួរសំណួរទៀតថា តើជនជាប់ចោទ អៀង ធីរិទ្ធ អាចអង្គុយ ឬឈរបានរយៈពេលប៉ុន្មាននាទី? លោកវេជ្ជបណ្ឌិត លីនណា បានឆ្លើយតបថា តាមបទពិសោធន៍របស់លោក ជនជាប់ចោទ អៀង ធីរិទ្ធ អាចផ្តល់សម្ភាសន៍ជាមួយលោកបានក្នុងរយៈពេលពីរម៉ោងដោយមិនមានបញ្ហាអ្វីទេ ។ ឆ្លើយតបទៅនឹងសំណួរដែលសួរទាក់ទងនឹងសមត្ថភាពយល់ដឹងពីបទចោទរបស់ជនជាប់ចោទ អៀង ធីរិទ្ធ លោកបានបញ្ជាក់ថា ជនជាប់ចោទរូបនេះ មានសមត្ថភាពខ្លះក្នុងការយល់ពីបទចោទ ។ បន្ទាប់ពីការបញ្ចប់សំណួរពីសហព្រះរាជអាជ្ញារងជាតិ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុល បានសួរសំណួរទៅកាន់អ្នកជំនាញថា តើជនជាប់ចោទអាចអានកាសែតជាភាសាបរទេសបានដែរឬទេ? លោកវេជ្ជបណ្ឌិត លីនណា បានឆ្លើយថា ជនជាប់ចោទបានអានអត្ថបទកាសែតមួយផ្នែកនៅក្នុងប្រព័ន្ធអ៊ីនធើណែតដែលលោកបានបង្ហាញ ។ លោកសហព្រះរាជអាជ្ញាបន្តទៀតថា តើជនជាប់ចោទយល់ពីគោលបំណងនិងផលវិបាកនៃនីតិវិធីឬទេ? អ្នកជំនាញរូបនេះបានឆ្លើយតបថាជនជាប់ចោទអាចយល់ពីផលវិបាកនៃនីតិវិធីដោយលំបាក ។

#### ៣) មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកមេធាវី ហុង គឹមសួន ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរសំណួរមួយចំនួនទៅអ្នកជំនាញទាំងពីរថា តើជនជាប់ចោទចុះខ្សោយ ឬក៏បាត់បង់ស្មារតី? លោកវេជ្ជបណ្ឌិត លីណា ឆ្លើយថា មិនទាន់បាត់បង់នៅឡើយទេ គឺគ្រាន់តែចុះខ្សោយស្មារតីប៉ុណ្ណោះ ។ លោកបន្តទៀតថា តើជនជាប់ចោទអាចចូលរួមសវនាការដែលមានរយៈខ្លីមិនដល់ពីរម៉ោងបានដែរឬទេ? អ្នក

ជំនាញ ហ្វាហ្វែរុល បានឆ្លើយថា បើលោកមានន័យថា ចំពោះការចូលរួមខាងរូបរាងកាយក្នុងការចូលរួមសវនាការនោះគឺត្រឹមត្រូវហើយ ។

### ឃ) តើសំណុំរឿងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គួរតែផ្តាច់ចេញឬទេ?

នៅក្នុងសវនាការនេះ តុលាការបានផ្តល់ឱកាសឲ្យភាគីទាំងអស់ធ្វើកំណត់សម្គាល់ទាក់ទងនឹងបញ្ហាបំបែកសំណុំរឿងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ថាតើមានការប៉ះពាល់យ៉ាងណាចំពោះជនជាប់ចោទដទៃទៀតក្នុងការទទួលបានការជំនុំជម្រះមួយឆាប់រហ័សនិងប្រកបដោយយុត្តិធម៌ ។ សហព្រះរាជអាជ្ញាស្នើសុំមិនឲ្យមានការបំបែកសំណុំរឿងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ឡើយ ។ រីឯភាគីមេធាវីរបស់ជនជាប់ ចោទ អៀង សារី លោក ខាណាវ៉ាស បានធ្វើកំណត់សម្គាល់ដោយបញ្ជាក់អំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះឆាប់រហ័សដោយផ្តល់យោបល់ឲ្យបំបែកសំណុំរឿងជនជាប់ចោទ អៀង ធីរិទ្ធ ចេញដោយទុកពេលឲ្យព្យាបាលជនជាប់ចោទឲ្យមានកាយសម្បទា បញ្ញាស្មារតីជាមុនសិនមុននឹងធ្វើការជំនុំជម្រះ ទៅលើជននោះ ។ ចំពោះលោកមេធាវី ម៉ៃឃើល ផេស្តមេន តំណាងឲ្យជនជាប់ចោទ នួន ជា បានធ្វើកំណត់សម្គាល់ដោយមានគំនិតចង់ឲ្យតុលាការបំបែកសវនាការជាពីរប្រភេទ គឺសវនាការសម្រាប់ជនជាប់ចោទដែលអាចមានសុខភាពល្អចូលរួមបានពេញមួយថ្ងៃ និងមួយទៀតជាសវនាការសម្រាប់បុគ្គលដែលមិនមានកាយសម្បទា បញ្ញា ស្មារតីពេញលេញក្នុងការចូលរួមសវនាការ ។ គោលបំណងរបស់លោកមេធាវីរូបនេះ គឺចង់ឲ្យតុលាការបំបែកសំណុំរឿងរបស់ជនជាប់ចោទ នួន ជា ដាច់ដោយឡែកពីគេ ។ ចំពោះសហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ផ្ទាល់បានជូនជាយោបល់ដល់តុលាការចំពោះករណីរបស់កូនក្តីខ្លួនក្នុងគោលបំណងចង់ឲ្យតុលាការបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងកូនក្តីខ្លួន ដោយសំអាងលើកាយសម្បទា បញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ លោក ស្រីមេធាវី អេលីស បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងអាចនឹងមានការកាត់ផ្តាច់នីតិវិធី ដោយពិនិត្យទៅលើភស្តុតាងជាក់ស្តែងនៅក្នុងការសម្រេចពីកាយសម្បទា បញ្ញា ស្មារតីរបស់ជនជាប់ចោទ លើកលែងតែមានភស្តុតាងផ្ទុយពីនេះ ។ លោកស្រីបានបន្តទៀតថា ប្រសិនបើតុលាការរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានកាយសម្បទា បញ្ញា ស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ តុលាការអាចមានវិធានការក្នុងការតាមដានសុខភាព ឬកាត់ផ្តាច់ជនជាប់ចោទនេះផ្សេង ដោយសារតែជនជាប់ចោទត្រូវការជំនួយច្រើន ។ ម្យ៉ាងទៀត បើតាមលក្ខខណ្ឌរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អាចប្រសើរនៅពេលដែលខ្លួនបានរស់នៅក្នុងបរិស្ថានផ្សេង ។ ដូចនេះតុលាការអាចនឹងដោះលែងឲ្យនៅក្រោយឃុំជាបណ្តោះអាសន្ន ។ ចំណែកមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន មិនបានធ្វើការកត់សម្គាល់អ្វីទេ ដោយសារតែក្រុមរបស់ខ្លួន រួមទាំងជនជាប់ចោទបានស្នើសុំមិនចូលរួមក្នុងសវនាការរយៈពេលពីរថ្ងៃនេះឡើយ ។

សម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រតុលាការឲ្យធ្វើការបំបែកសំណុំរឿងរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីកុំឲ្យមានការរាំងស្ទះដល់ដំណើរការនីតិវិធី និងដើម្បីឲ្យសវនាការប្រព្រឹត្តទៅបានឆាប់រហ័ស ។

### សន្និដ្ឋាន

គម្រោងសំណងទាំងឡាយដែលសហមេធាវីនាំមុខបានបង្ហាញជូនទៅអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១១ គឺគ្រាន់តែជាបណ្តុំនៃសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿងលេខ០០២ ដែលស្នើឡើងតាមរយៈមេធាវីរបស់ខ្លួន ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យ និងការវាយតម្លៃ ។ ការពិនិត្យ និងវាយតម្លៃទៅលើគម្រោងសំណង ដែលដាក់ជូនដោយសហមេធាវីនាំមុខ គឺដើម្បីធានាថាគម្រោងសំណងទាំងអស់នោះ នឹងអាចអនុវត្តបានភ្លាមៗ នៅក្រោយពេលដែលសាលក្រមចូលជាស្ថាពរ និងធានាពីលទ្ធភាពក្នុងការអនុវត្តសំណងប្រកបដោយប្រសិទ្ធិភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែគម្រោងសំណងដែលស្នើឡើងមិនមែនសុទ្ធតែអាចទទួលយកដោយអង្គជំនុំជម្រះឡើយ គម្រោងសំណងដែលស្នើដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងត្រូវបានបដិសេធចោល ប្រសិនបើគម្រោងសំណងដែលបង្កើតឡើងត្រូវចំណាយថវិកាច្រើនចំណាយ

ពេលវេលាច្រើនក្នុងការអនុវត្តសំណង ឬកម្មវត្ថុនៃសំណងដែលលើកឡើងមិនមានភាពច្បាស់លាស់ ។

ទោះបីជាយ៉ាងណា អង្គជំនុំជម្រះគួរតែពិចារណាអំពីការផ្តល់សំណងទៅដល់ជនរងគ្រោះក្នុងកម្រិតណាមួយដែលអាចធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្រោះថាសំណងរដ្ឋប្បវេណី គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ជនរងគ្រោះដែលបានបាត់បង់ញាតិមិត្ត ក្រុមគ្រួសារនិងអ្នកជាទីស្រឡាញ់ ដោយសាររបបខ្មែរក្រហម ហើយសំណងទាំងនោះអាចជាថ្នាំសម្រាប់ផ្សះផ្សារបួសផ្លូវចិត្តអ្នកដែលទទួលរងការបាត់បង់ទាំងអស់នោះ ។

ទោះបីជាការរកឃើញរបស់អ្នកជំនាញវិកលវិទ្យាទាំងពីររូបនៅក្នុងសវនាការមានការខុសប្លែកគ្នាមួយចំនួនទៅនឹងការរកឃើញរបស់លោកសាស្ត្រាចារ្យ ចន ខាំប៊ែល យ៉ាងណាក្តី ក៏លទ្ធផលជារួមនៅតែបង្ហាញថា ស្ថានភាពសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលបច្ចុប្បន្នអាចនឹងធ្វើឲ្យប៉ះពាល់ទៅដល់កិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការ ។ អ្នកជំនាញវិកលវិទ្យាបានវាយតម្លៃថាស្ថានភាពសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានភាពលំបាកក្នុងការចូលរួមនៅក្នុងសវនាការនិងពិបាកក្នុងការចងចាំ ។ លទ្ធផលនៃការរកឃើញរបស់អ្នកជំនាញថ្មីៗនេះនឹងក្លាយទៅជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់អង្គជំនុំជម្រះយកមកធ្វើការពិចារណា និងសម្រេចថាតើអង្គជំនុំជម្រះគួរតែដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យនៅជាប់ឃុំក្នុងផ្ទះ ដោយស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ឬបន្តសំណុំរឿងរបស់ជនជាប់ចោទ ដោយផ្តាច់ករណីរបស់ អៀង ធីរិទ្ធ ចេញដើម្បីពន្លឿនដំណើរនីតិវិធី ។

**ប្រតិកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីជុំវិញទិដ្ឋភាពក្នុងសវនាការ**

***ឈ្មោះ ឯក ស៊ីបូរ៉ាន ភេទស្រី អាយុ ៦០ឆ្នាំ រស់នៅស្រុកត្រាំកក ខេត្តតាកែវ ។***

“នៅក្នុងសវនាការខ្ញុំបានឮអ្នកជំនាញគេនិយាយថាជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺផ្លូវចិត្ត និងជំងឺខួរក្បាល តែទោះបីជាយ៉ាងម៉េច ក៏ខ្ញុំមិនមានចិត្តអាណិតចំពោះរូបគាត់ដែរ ព្រោះជនជាប់ចោទនេះហើយដែលសម្លាប់ក្រុមគ្រួសាររបស់ខ្ញុំអស់៤៤នាក់ ។ ការណ៍ដែលតុលាការថាជនជាប់ចោទមិនទាន់អាចកាត់ទោសភ្លាមៗ ត្រូវរង់ចាំព្យាបាល និងតាមដានជំងឺ ក្នុងចិត្តខ្ញុំដែលជាជនរងគ្រោះគឺមានការអាក់អន់ចិត្តនឹងការសម្រេចដូច្នេះ ។ ដោយសារសម្រាប់ជនរងគ្រោះដែលត្រូវពួកខ្មែរក្រហមសម្លាប់ គេត្រូវបានខ្មែរក្រហមបង្ខំឲ្យកាប់រណ្តៅខ្លួនឯង ហើយវ៉ៃសម្លាប់ទម្លាក់ក្នុងរណ្តៅនោះតែម្តង ។ ប៉ុន្តែសម្រាប់ជនជាប់ចោទនៅពេលនេះវិញ គេនៅមានម៉ាស៊ីនត្រជាក់ គេនៅមានកូនតាមថែ មិនដូចជនរងគ្រោះដែលត្រូវបែកបាក់គ្រួសារបែកបាក់បងប្អូនទាំងអស់ឡើយ ។

ចំពោះបញ្ហាសំណងវិញ បើអន្តរជាតិគេយល់ថា មិនអាចយកឈាមមកសងឈាម ខ្ញុំសូមឲ្យគេទៅធ្វើបុណ្យនៅកន្លែងគុកសម្លាប់មនុស្សដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹងអំពីការកាប់សម្លាប់នៅសម័យនោះ និងស្នើសុំតុលាការកាត់ក្តីឲ្យបានឆាប់រហ័សកុំទុកឲ្យជនជាប់ចោទមានជំងឺហើយស្លាប់មុនការកាត់ក្តី ព្រោះទាំងជនជាប់ចោទ និងជនរងគ្រោះសុទ្ធតែមានអាយុច្រើនដូចគ្នា ។”

***ឈ្មោះ រស់ ស៊ីផាន់ រស់នៅស្រុកកោះអណ្តែត ខេត្តតាកែវ ។***

“ទោះបីជាតុលាការរកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺមិនអាចចូលរួមក្នុងតុលាការបានក៏ដោយ ក៏ខ្ញុំសុំឲ្យតុលាការត្រូវតែឃុំគាត់ទុក មិនត្រូវដោះលែងឡើយ ព្រោះខ្លួនខ្ញុំផ្ទាល់ធ្លាប់ត្រូវបានគេចាប់ដាក់គុកមន្ទីរតាមាន់ នៅខេត្តកំពត ហើយខ្ញុំដើរមិនរួចរហូតដល់ថ្នាក់ត្រូវលូន ។ ដូច្នេះទោះបីជាជនជាប់ចោទស្លាប់ក៏មិនត្រូវដោះលែងដែរ ហើយត្រូវដាក់ខ្នោះមឈូសទៀតថែមទៀតទើបអស់ចិត្ត ។”

***ឈ្មោះ ជី ហុន អាយុ ៨៣ឆ្នាំ រស់នៅស្រុកកោះអណ្តែត ខេត្តតាកែវ ។***

“ពេលឪពុកខ្ញុំឈឺ ពួកខ្មែរក្រហមថាឪពុករបស់ខ្ញុំឈឺពុត ហើយគេដាក់រទេះសេះយកទៅបាត់ មិនដឹងថាគេយកទៅសម្លាប់ឬមួយយកទៅណាទេ ប៉ុន្តែសម្រាប់ជនជាប់ចោទ អៀង ធីរិទ្ធ វិញនៅមានពេទ្យព្យាបាល នៅសួរដេញដោល ។ ខ្ញុំមិនអាណិតជនជាប់ចោទ អៀង ធីរិទ្ធ ឡើយ ទោះបីជាគេរកឃើញថា គាត់មានជំងឺក៏ដោយ ព្រោះពេលដែលខ្មែរក្រហមនាំយកឪពុកខ្ញុំទៅ គេមិនបានសួរដេញដោលសូម្បីមួយម៉ាត់ គេមកយកគាត់ចេញតែម្តង ដោយគ្រាន់តែប្រាប់ថាយកទៅរៀនសូត្រ ។ ខ្ញុំសូមឲ្យតុលាការត្រូវតែរកយុត្តិធម៌ឲ្យឪពុករបស់ខ្ញុំ” ។

# ការវិវឌ្ឍថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*ដោយ លឹម ជ័យទត្ត, ចាន ប្រាថ្នា និង គឹម ម៉ារីយ៉ាន*

## ■ អ្វីទៅជាវិធានការសំណង និងវិធានការក្រៅប្រព័ន្ធតុលាការ នៅក្នុងបរិបទតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

### សេចក្ដីផ្ដើម

ក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ លើករណីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច កន្លងមក ដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍របស់ខ្លួនទៅអង្គជំនុំជម្រះតុលាការកំពូលជំទាស់នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការផ្ដល់សំណងជូនជនរងគ្រោះ ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំស្ទើរតែទាំងអស់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយសម្រេចយល់ព្រមផ្ដល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនូវសំណើត្រឹមពីរតែប៉ុណ្ណោះ ទី១) គឺការបញ្ចូលឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ចូលទៅក្នុងសាលក្រម និងទី២) ប្រមូលចងក្រងសេចក្ដីថ្លែងសុំអភ័យទោសទាំងអស់និងការទទួលស្គាល់ការទទួលខុសត្រូវដែល កាំង ហ្គេកអ៊ាវ ហៅ ឌុច ធ្វើឡើងក្នុងអំឡុងពេលសវនាការដាក់បង្ហោះលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[១]

វិធាន ២៣ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនេះបានបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្ដល់តែសំណងផ្លូវចិត្ត និងជាសមូហភាពដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។[២] អង្គជំនុំជម្រះមិនមានសមត្ថកិច្ចផ្ដល់សំណងជាប្រាក់ក្នុងលក្ខណៈបុគ្គលទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដូចជាតុលាការសាមញ្ញនៅកម្ពុជាទេ ។[៣] ផលវិបាកបែបនេះគឺដោយសារតែចំនួនដ៏ច្រើននៃដើមបណ្ដឹងរដ្ឋប្បវេណីនិងផលវិបាកក្នុងការកំណត់បរិមាណនៃការបាត់បង់ដែលជនរងគ្រោះបានទទួលរង ។[៤]

ដើម្បីដោះស្រាយបញ្ហានេះ កិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្ដីសម្រេចមួយផ្ដល់អំណាចដល់អង្គភាពគាំពារជនរងគ្រោះ តាមរយៈការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងនៅខែកញ្ញា ឆ្នាំ២០១០៥ ដោយផ្ដល់ផលប្រយោជន៍ដល់ជនរងគ្រោះឲ្យបានកាន់តែទូលំទូលាយជាងមុន ដើម្បីបង្កើត និងអនុវត្តកម្មវិធី និងវិធានការថ្មីៗដែលកើតឡើង

---

[១] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ លើសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច កថាខណ្ឌ ៦៨២ និង៦៨៣ ។

[២] វិធាន ២៣ ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើវិសោធនកម្មថ្ងៃទី០៣ ខែសីហា ២០១១ ។

[៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ លើសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទំព័រ៣៩៦ (ភាសាខ្មែរ) កំណត់សម្គាល់យោងជើងទំព័រលេខ ១១៨៤ ។

[៤] ដូចខាងលើ ។

[៥] សូមមើលវិធាន២៣ ស្ទួនបួន៣ នៃវិធានផ្ទៃក្នុង ដែលត្រូវបានធ្វើវិសោធនកម្មលើកទី៦ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ ដោយកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅក្រៅកិច្ចដំណើរការនីតិវិធីតុលាការជាផ្លូវការ ។[៦] វិធានការទាំងឡាយនេះអាចត្រូវបានបង្កើតឡើងដោយមានកិច្ចសហការជាមួយទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលនៅក្រៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលផ្តល់លទ្ធភាពក្នុងការបង្កើតនូវកម្មវិធីទូលំទូលាយជាងមុន ហើយអាចសម្រេចបានក្នុងវង្វង់សមត្ថភាពនិងធនធានដែលមាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ វិធានការទាំងឡាយដែលរៀបរាប់ខាងលើត្រូវបានស្គាល់ថាជាវិធានការពាក់ព័ន្ធទៅនឹងសំណងនៅក្នុងតុលាការ ។[៧]

## ១) វិធានការពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការ

វិធានការពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការគឺជាមធ្យោបាយថ្មីមួយដែលបង្កើតឡើងដោយលក្ខណៈឯករាជ្យដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់នៃការទទួលបានសំណងរដ្ឋប្បវេណីតាមវិធីសាស្រ្តដែលធ្លាប់អនុវត្តនាពេលកន្លងមក ។[៨] វិធានការសំណងនេះ មិនមែនបង្កើតឡើងក្នុងន័យឆ្លើយតបទៅនឹងការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទឡើយ ក៏ប៉ុន្តែដើម្បីធានាថាសំណងជាក់ស្តែងដែលផ្តល់ដោយប្រភពពីខាងក្រៅ ដែលទទួលស្គាល់ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអនុវត្តដោយឆាប់រហ័សបន្ទាប់ពីសាលក្រមចូលជាស្ថាពរ ។[៩] វិធាន២៣ស្ទួនបួន(៣)(ខ) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រគល់ភារកិច្ចក្នុងការបង្កើតគម្រោងនានាពាក់ព័ន្ធនឹងវិធានការសំណងជូនអង្គភាពគាំពារជនរងគ្រោះដើម្បីចាត់ចែង និងអនុវត្តន៍ ដោយសារតែអង្គភាពនេះកំពុងតែធ្វើការមួយចំនួនទាក់ទងទៅនឹងវិធានការក្រៅប្រព័ន្ធតុលាការដែរ ។[១០] ដើម្បីឲ្យសំណងជាក់ស្តែងដែលផ្តល់ដោយប្រភពពីខាងក្រៅអាចអនុវត្តបានដោយឆាប់រហ័ស បន្ទាប់ពីសាលក្រមចូលជាស្ថាពរ អង្គភាពគាំពារជនរងគ្រោះត្រូវរៀបចំសំណង(ជាលក្ខណៈបច្ចេកទេសតាមរយៈការគ្រប់គ្រងគម្រោង) ក្នុងពេលតំណាលគ្នាទៅនឹងដំណើរការសវនាការ ដែលមានមន្ត្រីគ្រប់គ្រងគម្រោងម្នាក់ជាអ្នកទទួលបន្ទុកលើការរៀបចំទម្រង់នៃសំណងទាំងអស់ដែលបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[១១] ហើយមន្ត្រីគ្រប់គ្រងគម្រោងនេះនឹងត្រូវធានាលើបញ្ហាថវិកា និងការត្រៀមខ្លួនរួចជាស្រេចក្នុងការអនុវត្តនូវសំណងនេះនៅពេលសាលក្រមចូលជាស្ថាពរ ។[១២] ដើម្បីទទួលបានសំណងដែលស្នើសុំអង្គជំនុំជម្រះបានតម្រូវឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានកិច្ចសហការស្អិតរមួតជាមួយនឹងមន្ត្រីគ្រប់គ្រងគម្រោងកម្មវិធីសំណងចាប់តាំងពីដំណាក់កាលដំបូងនៃការចាប់ផ្តើមនីតិវិធីក្នុងសំណុំរឿង ដើម្បីធានាថាបណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់មានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស មានតួលេខច្បាស់លាស់

---

[៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ប្រកាសនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ លើសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទំព័រ៣៩៨ (ភាសាខ្មែរ) កំណត់សម្គាល់យោងជើងទំព័រលេខ ១១៨៩ ។

[៧] ដូចខាងលើ ។

[៨] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

[៩] ដូចខាងលើ ។

[១០] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

[១១] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

[១២] ដូចខាងលើ ។

និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត ។[១៣] ទោះបីជាយ៉ាងណាក៏ដោយ វិធានការសំណងដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងត្រូវបានបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើគម្រោងសំណងដែលបង្កើតឡើងនោះ ត្រូវចំណាយថវិកាច្រើន ចំណាយពេលវេលាច្រើន ឬការបង្ហាញពីកម្មវត្ថុនៃសំណងពុំមានភាពច្បាស់លាស់ ។[១៤] វិធានការនានាដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំតាមរយៈអង្គភាពគាំពារជនរងគ្រោះ ត្រូវបញ្ជាក់ជាមុនអំពីខ្លឹមសារជាក់លាក់ស្តីពីសំណងនៅដំណាក់កាលដំបូង[១៥] ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានធ្វើនៅក្នុងសវនាការបឋម[១៦] និងសវនាការស្តីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[១៧] ដើម្បីធានាអំពីវិសាលភាព និងប្រសិទ្ធភាពនៃវិធានការដែលបានស្នើសុំ និងដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពិនិត្យមើល និងផ្តល់ការណែនាំថាតើសំណងដែលបានស្នើសុំនោះ ស្របជាមួយក្របខ័ណ្ឌគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ។[១៨] គម្រោងទាក់ទងនឹងវិធានការសំណងដែលនឹងត្រូវអនុវត្តដោយអង្គភាពគាំពារជនរងគ្រោះត្រូវបានចងក្រងជាប្អូនជំពូក ដូចជាគម្រោងរំឭកការចងចាំ គម្រោងស្តារនីតិសម្បទាឡើងវិញ គម្រោងចងក្រងឯកសារ និងការអប់រំ និងគម្រោងសំណងផ្សេងៗ ។[១៩]

## ២) វិធានការក្រៅប្រព័ន្ធតុលាការ

ចំណែកឯវិធានការក្រៅប្រព័ន្ធតុលាការ គឺជាវិធានការដែលពុំជាប់ពាក់ព័ន្ធនឹងសំណងនៅក្នុងតុលាការ ។ វិធានការក្រៅប្រព័ន្ធតុលាការមិនមែនជាសំណងនោះទេ ប៉ុន្តែវាជាការឆ្លើយតបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះជនរងគ្រោះ និងប្រជាជនកម្ពុជាទូទាំងប្រទេសឲ្យទទួលបាននូវការផ្សះផ្សា និងការព្យាបាលរបួសផ្លូវចិត្ត ។[២០] ការឆ្លើយតបនៃវិធានការក្រៅប្រព័ន្ធតុលាការនេះមានលក្ខណៈជាសមូហភាព និងផ្លូវចិត្តដូចគ្នានឹងទម្រង់នៃសំណងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះដែរ ។ អង្គភាពគាំពារជនរងគ្រោះមានភារកិច្ចជាអ្នក

---

១៣ ដូចខាងលើ ។

១៤ ដូចខាងលើ ។

១៥ ដូចខាងលើ ។ សូមមើលវិធាន ៨០ ស្ទួន(៤) នៃវិធានផ្ទៃក្នុងដែលចែងថា ៖ "អង្គជំនុំជម្រះសាលាដំបូងអាចណែនាំសហមេធាវីនាំមុខឲ្យផ្តល់ឯកសារជាក់លាក់ស្តីអំពីសំណងដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសមូហភាព ក្នុងអំឡុងពេលជាក់លាក់ដែលបានកំណត់ដោយអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣)(ខ) ។ នៅដំណាក់កាលក្រោយមកទៀត អង្គជំនុំជម្រះនឹងត្រូវកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់សហមេធាវីនាំមុខក្នុងការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្តនិងសមូហភាព ។"

១៦ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមលើសំណុំរឿងលេខ០០២ ពីថ្ងៃទី២៧ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ប្រឆាំងនឹងជនជាប់ចោទបួនរូប រួមមានជនជាប់ចោទ ខៀវ សំផន នួន ជា អៀង សារី និងអៀង ធីរិទ្ធ ។

១៧ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តីពីការកំណត់ជាក់លាក់នូវសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសវនាការលើសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ពីថ្ងៃទី១៩ដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ។

១៨ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

១៩ សូមអានអត្ថបទ : សវនាការស្តីពីការកំណត់ជាក់លាក់នូវសំណង និងសវនាការលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ពីថ្ងៃទី១៩-២០ ខែតុលា ឆ្នាំ២០១១ របស់មជ្ឈមណ្ឌលឯកសារសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១១ ដោយ ឌី សុជាតា និង លីម ជ័យទត្ត ។

២០ ការឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់ លោក គាន់ វិសាល មន្ត្រីគ្រប់គ្រងគម្រោងទាក់ទងនឹងវិធានការក្រៅប្រព័ន្ធតុលាការរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្នុងវេទិកាថ្នាក់តំបន់នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿងលេខ ០០២ ដែលបានប្រព្រឹត្តធ្វើនៅខេត្តកំពង់ចាម កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

សម្របសម្រួលគម្រោងវិធានការក្រៅប្រព័ន្ធតុលាការតាមរយៈការសហការជាមួយម្ចាស់ជំនួយរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះនិងប្រជាជនទូទាំងប្រទេស ។ វិធានការក្រៅប្រព័ន្ធតុលាការអាចអនុវត្តបានគ្រប់ពេលវេលាគ្រប់ទីកន្លែង ដោយមិនចាំបាច់មានសាលក្រមពីតុលាការសម្រេចឲ្យអនុវត្តដូចជាសំណងដែលដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារទៅអង្គជំនុំជម្រះឡើយ ។[២១] ទោះបីជានៅក្នុងករណីជនជាប់ចោទត្រូវបានតុលាការរកឃើញថាជាជនក្រីក្រ ឬទទួលមរណភាពក៏ដោយ វិធានការក្រៅប្រព័ន្ធតុលាការនឹងនៅតែអាចបន្តអនុវត្តគម្រោងនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះ និងប្រជាជនកម្ពុជាទូទាំងប្រទេដដែលបានទទួលរងការបាត់បង់ និងរបួសផ្លូវចិត្តបានដដែល ។ ការអនុវត្តបែបនេះ គឺដើម្បីផ្តល់ប្រយោជន៍ទៅដល់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយ ។

## សន្និដ្ឋាន

ទោះបីជាវិធានការក្រៅប្រព័ន្ធតុលាការ និងវិធានការសំណងក្នុងតុលាការផ្តល់ប្រយោជន៍ទៅដល់ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងណាក៏ដោយ ការអនុវត្តវិធានការទាំងនេះអាចជួបប្រទះបញ្ហាប្រឈមចម្បងៗមួយចំនួនដូចជាការខ្វះខាតធនធាននិងសមត្ថភាពនៅមានកម្រិតរបស់អង្គភាពគាំពារជនរងគ្រោះ ។[២២]

ប្រភពថវិកាដែលនឹងត្រូវយកមកអនុវត្តគម្រោងសំណងក្រៅប្រព័ន្ធតុលាការនេះទៀតសោតបានក្លាយទៅជាបន្ទុកថ្មីមួយបន្ថែមលើអង្គភាពគាំពារជនរងគ្រោះ ។ ដូច្នេះអង្គភាពគាំពារជនរងគ្រោះ ចាំបាច់ត្រូវតែស្វែងរកថវិកានិងការសម្របសម្រួលពីរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូរម្ចាស់ជំនួយនានាដើម្បីឲ្យការអនុវត្តគម្រោងទាំងនេះអាចឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានកាន់តែឆាប់រហ័ស ។


អគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

---

២១ ការឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់ លោក គាន់ វិសាល មន្ត្រីគ្រប់គ្រងគម្រោងទាក់ទងនឹងវិធានការក្រៅប្រព័ន្ធតុលាការរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្នុងវេទិការថ្នាក់តំបន់នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿងលេខ ០០២ ដែលបានប្រព្រឹត្តធ្វើនៅខេត្តកំពង់ចាម កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ។

២២ សូមមើល សាលាកបត្រព័ត៌មានរបស់អង្គភាពគាំពារជនរងគ្រោះ “ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ឆ្នាំទី១ ច្បាប់ទី២ ខែមករា-មីនា ឆ្នាំ២០១១ ទំព័រ៩ (ភាសាខ្មែរ) ។

## ■ ការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២

### សេចក្តីផ្តើម

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ជាផ្នែកតូចៗដែលនឹងធ្វើឲ្យមានការជំនុំជម្រះជាច្រើនដំណាក់កាល ។[១] ដោយដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ មានអង្គហេតុច្រើន និងបទចោទស្មុគស្មាញដែលការជំនុំជម្រះលើសំណុំរឿងទាំងមូលអាចនឹងប្រើរយៈពេលយូរ អង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកអង្គហេតុ និងបទចោទជាផ្នែកតូចៗដាច់ចេញពីគ្នា ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើការវិនិច្ឆ័យលើអង្គហេតុនិងបទចោទមួយចំនួនដោយប្រើរយៈពេលខ្លីសមស្រប ។[២] មូលហេតុចម្បងដែលនាំឲ្យមានការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះគឺដោយមានក្តីបារម្ភចំពោះសមត្ថភាពចូលរួមរបស់ជនជាប់ចោទ ទាំងផ្លូវកាយ និងស្មារតីនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះដែលមានរយៈពេលវែង ។[៣] ដីកានេះមានវិសាលភាពកម្រិតត្រឹមតែការបំបែកបទចោទប្រកាន់លើជនជាប់ចោទទាំង៤រូប ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ ហើយវាពុំមានវិសាលភាពបំបែកជនជាប់ចោទចេញពីសំណុំរឿងឡើយ ។[៤] តែទោះបីជាយ៉ាងណាក៏ដោយ ការពិភាក្សាលើការបំបែកជនជាប់ចោទចេញពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ កំពុងស្ថិតនៅក្រោមការពិចារណារបស់សាលាដំបូងនៅឡើយ ។[៥] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះបានកំណត់ពីអង្គហេតុ និងបទចោទដែលនឹងត្រូវជំនុំជម្រះនៅដំណាក់កាលដំបូងរួមមាន៖ ទី១) រចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ ទី២) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗ បានទទួលការចាត់តាំងនូវតួនាទីទាំងនោះ ទី៣) តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំងក្របខ័ណ្ឌនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ទី៤) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទី៥) ការចោទប្រកាន់លើអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងទី៦) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញលើកលែងដោយហេតុផលសាសនា) ការជម្លៀសប្រជាជនដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ។[៦]

បន្ថែមពីលើនេះ ក្នុងករណីចាំបាច់ដើម្បីធានាសិទ្ធិការពារខ្លួនប្រកបដោយប្រសិទ្ធិភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងអាចនឹងធ្វើការដាក់បញ្ចូលបន្ថែមនូវផ្នែកផ្សេងៗទៀតនៃដីកាដំណោះស្រាយ ដើម្បីធ្វើការសម្រេចក្នុងដំណាក់កាល

---

[១] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងឯកសារលេខ E124 ។

[២] ដូចខាងលើ ។ កថាខណ្ឌទី៨ ។

[៣] សេចក្តីសម្រេចរបស់សាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌទី១១ នៃឯកសារលេខ E124/7 ។

[៤] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុង កថាខណ្ឌទី៤ ឯកសារលេខ E124 ។

[៥] សវនាការថ្ងៃទី១៩ ដល់ទី២០ ខែតុលា ឆ្នាំ២០១១ ស្តីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូងស្នើឲ្យភាគីទាំងអស់ធ្វើការកត់សម្គាល់លើលទ្ធភាពនៃការបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ ទាំងមូលដែលមានជនជាប់ចោទបួនរូប ។

[៦] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុង កថាខណ្ឌទី៥ ឯកសារលេខ E124 ។

ដំបូងនេះ ។[៧] ចំណែកអង្គហេតុ និងបទចោទផ្សេងៗទៀតដែលនៅសល់ក្នុងដីកាដំណោះស្រាយនឹងត្រូវយកមកជំនុំជម្រះក្នុងដំណាក់កាលក្រោយៗ ។[៨] តែទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់នូវព័ត៌មានលម្អិតអំពីផ្នែកនានានៅក្នុងដីកាដំណោះស្រាយដែលត្រូវយកមកជំនុំជម្រះនៅក្នុងក្របខណ្ឌនៃដំណាក់កាលដំបូងនៃសំណុំរឿង០០២ដែរ ។[៩] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបានកំណត់ពីវិសាលភាពនៃការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត ។[១០]

ក្រោយពីចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីពិចារណាឡើងវិញនូវដីកាសម្រេចបំបែកសំណុំរឿងនេះ ។[១១] សហមេធាវីនាំមុខដំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះបានធ្វើឲ្យប៉ះពាល់យ៉ាងធំធេងដល់ការចូលរួមនិងការទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។[១២] សំណើទាំងនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូងច្រានចោល[១៣] ដោយអង្គជំនុំជម្រះយល់ឃើញថា ការពិចារណាឡើងវិញនេះនឹងធ្វើឲ្យមានការពន្យាពេលសវនាការលើអង្គសេចក្តីដែលខ្លួនបានប្រកាសថានឹងចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ខាងមុខនេះ ។[១៤]

ដោយសេចក្តីសម្រេចច្រានចោលសំណើឲ្យពិចារណាឡើងវិញនូវដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមិនបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ[១៥] សំណួរចោទឡើងថា តើការបំបែកកិច្ចដំណើរការនីតិវិធីនេះ ផ្តល់ផលប្រយោជន៍ និង មានផលប៉ះពាល់អ្វីខ្លះ?

## ១) ផលប្រយោជន៍នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២

វិធាន ៨៩ស្ទួន២នៃវិធានផ្ទៃក្នុងចែងថា ៖

«នៅពេលប្រយោជន៍យុត្តិធម៌តម្រូវនៅដំណាក់ណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ពន្ធ័នឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ពន្ធ័នឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។»[១៦]

យោងតាមវិធាននេះ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ ដោយអះអាង

---

[៧] ដូចខាងលើ កថាខណ្ឌទី៦ ។

[៨] ដូចខាងលើ កថាខណ្ឌទី៧ ។

[៩] សូមមើលបញ្ជីឈ្មោះ «កថាខណ្ឌ និងផ្នែក» នៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនៃសំណុំរឿង០០២ ឯកសារលេខ E124/7.1 ។

[១០] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងកថាខណ្ឌទី៨ ឯកសារលេខ E124 ។

[១១] ការជូនដំណឹងអំពីសំណើសហព្រះរាជអាជ្ញាស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចក្នុងដីកាបំបែកនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួន (២) ឯកសារលេខ E124/1 ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ និងការជូនដំណឹងអំពីសំណើសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំពិចារណាឡើងវិញចំពោះការសម្រេចក្នុងដីកាបំបែកនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួន (២) E124/4 ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ ។

[១២] ឯកសារលេខ E124/4 កថាខណ្ឌទី៥ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ ។

[១៣] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំរបស់សហព្រះរាជអាជ្ញាឲ្យពិចារណាឡើងវិញលើដីកាបំបែកកិច្ចដំណើរការនីតិវិធី «**បដិសេធ**សំណើសុំឲ្យមានការពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី» ឯកសារលេខ E124/7 ។

[១៤] សេចក្តីសម្រេចរបស់សាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌទី១១ ឯកសារលេខ E124/7 ។

[១៥] ដូចខាងលើ ។ កថាខណ្ឌទី៥ ។

[១៦] វិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (វិសោធនកម្មលើកទី៨) ។

ថាការបំបែកកិច្ចដំណើរការនីតិវិធីនេះគឺដើម្បីប្រយោជន៍នៃយុត្តិធម៌ ។[១៧] ពាក្យថា «ដើម្បីផលប្រយោជន៍យុត្តិធម៌» អង្គជំនុំជម្រះផ្តោតទាំងយុត្តិធម៌សម្រាប់ជនរងគ្រោះ និងយុត្តិធម៌សម្រាប់ជនជាប់ចោទ (សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស) ។[១៨] ភាពចាស់ជរារបស់ជនជាប់ចោទទាំងបួនរូប ដែលត្រូវប្រឈមនឹងការកាត់ទោសលើបទល្មើសដ៏ស្មុគស្មាញ ហើយប្រើរយៈពេលយូរ គឺជាក្តីបារម្ភរបស់តុលាការដែលមានតួនាទីរកយុត្តិធម៌ជូនជនរងគ្រោះ ។ ដូចនេះការបំបែកកិច្ចដំណើរការនីតិវិធី គឺជាជម្រើសល្អបំផុតសម្រាប់ជនរងគ្រោះ[១៩] បើតុលាការមើលឃើញថាសុខភាពរបស់ជនជាប់ចោទជាបញ្ហាចោទដែលនឹងអាចរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីជំនុំជម្រះលើលើសំណុំរឿងទាំងមូល ។

ម្យ៉ាងទៀតជនរងគ្រោះមួយចំនួនធំមានវ័យចំណាស់ៗដែរ ហើយកំពុងទន្ទឹងរង់ចាំយុត្តិធម៌មួយប្រកបដោយអត្ថន័យនិងទាន់ពេលវេលា ។[២០] អង្គជំនុំជម្រះលើកឡើងបន្ថែមថា ការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះក្នុងគោលបំណង[២១] :

◆ ដើម្បីបែងចែកសំណុំរឿង ០០២ ទៅជាផ្នែកៗដែលអាចគ្រប់គ្រងបាន ដែលផ្នែកនីមួយៗត្រូវការពេលខ្លីក្នុងការសម្រេច ។

◆ ដើម្បីធានាថា ការជំនុំជម្រះដំណាក់កាលដំបូងបានរួមបញ្ចូលនូវការពិនិត្យយ៉ាងហ្មត់ចត់លើបញ្ហាជាមូលដ្ឋាននិងការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ទាំងអស់ ។

◆ ដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានា ដែលនៅសេសសល់ប្រឆាំងនឹងជនចាប់ចោទនៅក្នុងកាជំនុំជម្រះលើកក្រោយ ។

◆ ដើម្បីប្រតិបត្តិតាមលំដាប់នៃព្រឹត្តិការណ៍ និងឬលំដាប់លំដោយនៃដីកាដំណោះស្រាយ តាមដែលអាចធ្វើទៅបាន (រវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦) ។

◆ ដើម្បីធានាតាមដែលអាចធ្វើបានថា បញ្ហានានាដែលត្រូវបានពិនិត្យនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូងផ្តល់នូវមូលដ្ឋានមួយសម្រាប់ការពិចារណាអំពីទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្ម រួមតាមរយៈការរួមបញ្ចូលជនជាប់ចោទទាំងអស់ ។

◆ ដើម្បីជ្រើសរើសការចោទប្រកាន់លើអង្គហេតុទាំងឡាយដែលប៉ះពាល់ដល់ជនរងគ្រោះ ជាច្រើនតាមដែលអាចធ្វើបាន ។

អត្ថប្រយោជន៍មួយចំនួនទៀតផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូង តាមរយៈការបំបែកកិច្ចដំណើរការនីតិវិធីនេះ ។ សំណើជាច្រើន[២២] ដែលរង់ចាំការសម្រេចពីអង្គជំនុំជម្រះសាលដំបូងមុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី ត្រូវបានអង្គជំនុំជម្រះពន្យាពេលសម្រេចនៅពេលក្រោយ ព្រោះដោយសារសំណើសុំទាំងនោះមិនជាប់ពាក់ពន្ធ័អង្គហេតុនិងបទចោទដែលនឹងត្រូវយកវិនិច្ឆ័យទោសនៅក្នុងសវនាការដំណាក់កាលដំបូងនេះ ។[២៣]

---

[១៧] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុង កថាខណ្ឌទី៥ នៃឯកសារលេខ E124 ។

[១៨] ដូចខាងលើ ។ កថាខណ្ឌទី៨ ។

[១៩] កថាខណ្ឌទី៨នៃឯកសារលេខE124 «...ការបំបែកកិច្ចដំណើរការនីតិវិធី និងផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះអាចចេញសាលក្រមបាន បន្ទាប់ពីការជំនុំជម្រះខ្លីនេះ ដើម្បីការពារបាននូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យនិងទាន់ពេលវេលា...» ។

[២០] សេចក្តីសម្រេចរបស់សាលាដំបូងលើសំណើររបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើដីកាបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌទី១១ នៃឯកសារលេខ E124/7 ។

[២១] ដូចខាងលើ ។ កថាខណ្ឌទី១០ ។

[២២] សំណើរបស់ក្រុមមេធាវី អៀង សារី ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យទីកន្លែង ដើម្បីអាចសង្កេតមើលភូមិសាស្ត្រ សភាពនៃទីតាំង...»ឯកសារលេខ E113 ។ សូមមើលសំណើផ្សេងៗទៀតរបស់ អៀង សារី ដែលបានរៀបរាប់នៅក្នុងកំណត់សម្គាល់យោងជើងទំព័រទី៧ នៃឯកសារលេខ E124 ។

[២៣] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងកថាខណ្ឌទី៩ ឯកសារលេខ E124 ។

### ២) ផលប៉ះពាល់ដែលកើតចេញពីដីកាបំបែកកិច្ចដំណើរការនីតិវិធី

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះនឹងធ្វើឲ្យប៉ះពាល់យ៉ាងធំធេងទៅលើភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ និងការទាមទារសំណង ។[២៤] កថាខណ្ឌទី៨នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបានកំណត់ថា ៖

*«...ហេតុដូច្នេះការកម្រិតវិសាលភាពនៃអង្គហេតុដែលគ្រោងនឹងយកមកជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះ ពុំមានផលប៉ះពាល់ចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ ។ ចំណែកការទាមទារសំណងដែលធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏គួរគិតពិចារណាលើវិធាន២៣ស្ទួន(៤)(១)(ក) នៃវិធានផ្ទៃក្នុងផងដែរ ។»*[២៥]

នៅក្នុងការកំណត់នេះ អង្គជំនុំជម្រះហាក់ដូចជាសង្កត់ធ្ងន់ចំពោះតែសំណងដែលបានកំណត់នៅក្នុងចំណុច«ក» កថាខណ្ឌទី១ នៃវិធាន២៣ស្ទួន(៤) តែប៉ុណ្ណោះ ដែលអាចផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលជំនុំជម្រះលើកដំបូងនេះ ។

សំណួរសួរថា តើការកំណត់វិសាលភាពនៃការទាមទារសំណងនេះស្របទៅនឹងចរិតលក្ខណៈនៃសំណងផ្លូវចិត្ត និងសមូហភាព ដែលមានចែងក្នុងវិធានផ្ទៃក្នុងដែរឬទេ?

វិធាន២៣ស្ទួន៤(១) នៃវិធានផ្ទៃក្នុងចែងថា ៖

*«នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការទាំងឡាយដែល៖*

*ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទ ដែលត្រូវបានផ្តន្ទាទោស និង*

*ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ ។»*[២៦]

យោងតាមវិធាននេះ សំណងផ្លូវចិត្ត និងសមូហភាពត្រូវធ្វើឡើងតាមវិធានការ២យ៉ាងគឺ «ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរង» និង «ត្រូវផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងពីការខូចខាតនេះ» ។ ដូចនេះការណ៍ដែលដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីស្នើឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងដោយពិចារណាលើវិធាន២៣ស្ទួន៤(១)(ក) យ៉ាងជាក់លាក់នៅក្នុងដំណាក់កាលជំនុំជម្រះដំបូងនេះ អាចនឹងមានបញ្ហាចោទឡើងថា តើសំណងដែលមានចែងក្នុងវិធាន ២៣ស្ទួន ៤(១)(ខ) ត្រូវបានធានាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ ។

សរុបសេចក្តីមក ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះគឺជាអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលអនុញ្ញាតដោយច្បាប់ ។[២៧] ដូចនេះការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គប្បីគិតដល់ផលប្រយោជន៍យុត្តិធម៌ជាធំ ហើយការផ្តល់យុត្តិធម៌នេះត្រូវមានលក្ខណៈស្របតាមគោលបំណងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីទទួលបាននូវការផ្សះផ្សាជាតិមួយដ៏ពិតប្រាកដតាមរយៈការទទួលយករបស់ប្រជាជនកម្ពុជាលើលទ្ធផលដែលបានកើតចេញពីតុលាការនេះ ។

---

[២៤] ការជូនដំណឹងអំពីសំណើរបស់សហមេធាវីនាំមុខដំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌទី៥ ឯកសារលេខ E124/4 ។

[២៥] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុង កថាខណ្ឌទី៨ ឯកសារលេខ E124 ។

[២៦] វិធាន២៣ស្ទួនបួន(១)(ក) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[២៧] វិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ■ ការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង

### ១) សាវតានៃការិយាល័យសហចៅក្រមស៊ើបអង្កេត

ការិយាល័យសហចៅក្រមស៊ើបអង្កេតជាអង្គភាពឯករាជ្យមួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការិយាល័យនេះមានភារកិច្ចស៊ើបអង្កេតដោយខានពុំបានទៅលើបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[១] និងអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ។[២] ក្នុងករណីដែលលេចចេញនូវអង្គហេតុថ្មីពេលកំពុងធ្វើការស៊ើបអង្កេតនោះ សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានទៅសហព្រះរាជអាជ្ញាលើកលែងតែអង្គហេតុថ្មីនោះជាស្ថានទម្ងន់នៃអង្គហេតុចាស់ ។[៣] រហូតមកដល់ពេលបច្ចុប្បន្ននេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រេចបានការស៊ើបអង្កេតជាស្ថាពរលើសំណុំរឿងចំនួន២គឺ សំណុំរឿង ០០១ដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច និងសំណុំរឿង០០២ទាក់ទិនទៅនឹងមេដឹកនាំជាន់ខ្ពស់បួនរូប រួមមាន នួន ជា ខៀវ សំផន អៀង សារី និងអៀង ធីរិទ្ធ ។ អនុលោមតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាសំណុំរឿង ០០១និង ០០២ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ។[៤] ការិយាល័យសហចៅក្រមស៊ើបអង្កេតបាននឹងកំពុងបន្តស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី០៧ ខែកញ្ញា ២០០៩ ។[៥] បន្ទាប់ពីការស៊ើបអង្កេតលើសំណុំរឿងនីមួយៗត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយមួយ ។ ដីកាដំណោះស្រាយនោះជាសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ។[៦] សមាសភាពនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតរួម មានសហចៅក្រមស៊ើបអង្កេតខ្មែរ និងបរទេស និងមន្ត្រីជំនួយតាមការចាំបាច់[៧] ដូចជា មន្ត្រីនគរបាល យុត្តិធម៌ អ្នកស៊ើបអង្កេត និងក្រលាបញ្ជី ។[៨] មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញអាចអនុវត្តកាតព្វកិច្ចស៊ើបសួរទាំងឡាយណាដែលអាចមានប្រយោជន៍ដល់ការស៊ើបសួរតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ។[៩]

### ២) សាវតានៃការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

ចាប់តាំងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការក្នុងខែកុម្ភៈ ឆ្នាំ២០០៦ រហូតមកទល់ពេលបច្ចុប្បន្ននេះ គឺមានសហចៅក្រមបរទេសពីរូបហើយដែលធ្វើការលាលែងពីមុខតំណែង របស់ខ្លួន ។ លោកចៅក្រម ម៉ាកសែល ឡឺម៉ុង (*Marcel Lemonde*) គឺជាអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិដំបូងនៅ

---

*១ វិធាន៥៥(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៨) ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ។*

*២ វិធាន៥៥(២) នៃវិធានផ្ទៃក្នុង ។*

*៣ វិធាន៥៥(៣) នៃវិធានផ្ទៃក្នុង ។*

*៤ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh ។*

*៥ សំណុំរឿង០០៤, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh ។*

*៦ វិធាន៦៧ នៃវិធានផ្ទៃក្នុង ។*

*៧ វិធាន១៨(១) នៃវិធានផ្ទៃក្នុង ។*

*៨ វិធាន១៥,១៦,១៧ នៃវិធានផ្ទៃក្នុង ។*

*៩ វិធាន៥៥(១) នៃវិធានផ្ទៃក្នុង ។*

ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោក ម៉ាកសែល ឡឺម៉ុង បានទទួលតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីឆ្នាំ២០០៦ រហូតដល់ថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ ២០១០ ។[១០] ឡឺម៉ុង បានទទួលខុសត្រូវដឹកនាំការស៊ើបសួរនៅក្នុងសំណុំរឿងចំនួនពីរ គឺសំណុំរឿង០០១និងសំណុំរឿង០០២ដោយជោគជ័យ ។[១១] លោក ម៉ាកសែល ឡឺម៉ុង បានលាលែងពីតំណែងជាសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១០ ។[១២] មុនពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាកសែល ឡឺម៉ុង បានលាលែងពីតំណែង មានបញ្ហាមួយចំនួនកើតឡើងចំពោះការិយាល័យស៊ើបអង្កេត ។ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ សហមេធាវីការពារក្តីឲ្យជនត្រូវចោទ អៀង សារី បានដាក់ពាក្យបណ្តឹងជំទាស់ (បណ្តឹងសុំផ្លាស់ប្តូរ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិលោក ម៉ាកសែល ឡឺម៉ុង ។ ការសុំប្តឹងជំទាស់នេះ សហមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានលើកឡើងពីសម្តីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិរូបនេះដែលបាននិយាយនៅក្នុងកិច្ចប្រជុំមួយជាមួយនឹងបុគ្គលិកមួយចំនួននៃការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីខែសីហា ឆ្នាំ២០០៩ ។ ការចោទប្រកាន់ធ្វើឡើងដោយផ្អែកលើសំដីរបស់ចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺម៉ុង បាននិយាយក្នុងកិច្ចប្រជុំជាឯកជននោះថា "ខ្ញុំចង់ឲ្យពួកយើងស្វែងរកភ័ស្តុតាងដាក់បន្ទុកឲ្យបានច្រើនជាងភ័ស្តុតាងដោះបន្ទុក" ។ ពាក្យសម្តីទាំងអស់នេះត្រូវបានរកឃើញនៅក្នុងសេចក្តីថ្លែងការណ៍ចំនួនបីទំព័ររបស់លោក វេយនេ បាស្ទីន *(Waynee Bastin)* ដែលជាអតីតប្រធានអង្គភាពផ្នែកស៊ើបការណ៍និងផ្នែកវិភាគនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[១៣] សហមេធាវីការពារក្តីបានលើកឡើងថា ពាក្យសម្តីរបស់ចៅក្រម ឡឺម៉ុង បានបង្ហាញពីភាពលម្អៀងជាក់ស្តែងរបស់ចៅក្រម ឡឺម៉ុង និងភាពទំនងថា មានភាពលម្អៀងផងដែរ ។[១៤] សំណើដែលលើកឡើង ដោយសហមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ត្រូវបានបដិសេធចោលដោយមតិជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ ។ ក្រៅពីនេះមានលេចចេញនៅបញ្ហាផ្សេងទៀតដូចជានៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីប្រកាសព័ត៌មាន សូមធ្វើការកែតម្រូវនូវសេចក្តីរាយការណ៍ព័ត៌មានដែលមានលក្ខណៈខុសឆ្គង និងភន្តច្រឡំមួយចំនួនក្នុងសេចក្តីថា "សលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យថ្មីប្រាំនាក់ទៀត" (ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០) និង "ចៅក្រមសាលាក្តីខ្មែរក្រហមមិនបានចុះហត្ថលេខាឲ្យមានការស៊ើបអង្កេតថ្មីទេ" ឌឹ ខែមបូឌា ដេលី ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០) ដោយសហចៅក្រមស៊ើបអង្កេតបានប្រកាសថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាត់ទុកថាមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរពាក់ព័ន្ធនឹងបញ្ហាពេលវេលាសមស្របនៃចំណាត់ការលើការស៊ើបសួរក្នុងសំណុំរឿង០០៣ និង០០៤ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងបន្តដំណើរការងារ

---

[១០] *អំពីលោក ម៉ាកសែល ឡឺម៉ុង (Marcel Lemonde) , ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh/en/judicial-person/mr-marcel-lemonde ។*

[១១] *អត្ថបទមានចំណងជើងថា "ឡឺម៉ុង លើកឡើងនូវសំដីចុងក្រោយ" របស់ភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០១០ ។*

[១២] *អំពីលោក ម៉ាកសែល ឡឺម៉ុង, ការិយាល័យសហចៅក្រមស៊ើបអង្កេត, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh/en/judicial-person/mr-marcel-lemonde ។*

[១៣] *សាលដីកាលើពាក្យបណ្តឹងជំទាស់របស់ជនជាប់ចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេតចៅក្រម ម៉ាកសែល ឡឺម៉ុង ចេញថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩ ។ ឯកសារលេខ ៧ សូមមើល www.eccc.gov.kh/documents/court ។*

[១៤] *ដូចខាងលើ ។*

នេះតែម្នាក់ឯង ។[១៥] លោកសហចៅក្រមស៊ើបអង្កេត ម៉ាកសែល ឡឺមុង បានលើកឡើងនូវពាក្យចុងក្រោយរបស់គាត់ដោយការឆ្លើយតបសរសេរទៅកាន់កាសែតភ្នំពេញប៉ុស្តិ៍ថា “តុលាការត្រូវតែមានឯករាជ្យ និងអព្យាក្រឹត្យ” ហើយបានបន្ថែមទៀតថា “ឯករាជ្យពីរដ្ឋាភិបាលកម្ពុជា និងឯករាជ្យពីសាព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាលនានាផងដែរ ។”[១៦]

ក្រោយពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាកសែល ឡឺមុង បានលាលែងចេញពីតំណែង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ទៀតដើម្បីដំណើរការនីតិវិធីសំណុំរឿងបន្តទៀត ។ ការតែងតាំងនេះធ្វើឡើងដោយព្រះមហាក្សត្រ នរោត្តម សីហមុនី បានឡាយព្រះហត្ថលេខាតែងតាំងលោក ស៊ីកហ្វ្រេដ ប៊្លុង *(Siegfried Blunk)* ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០១០ ។[១៧] សហចៅក្រមអន្តរជាតិ ប៊្លុង ជនជាតិអាល្លឺម៉ង់ លោកបានបញ្ចប់ការសិក្សាផ្នែកច្បាប់នៅសកលវិទ្យាល័យ មុយនិច *(Murnich)* និងបានសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតស្តីពីច្បាប់អន្តរជាតិ ។ លោក ប៊្លុង ត្រូវបានតែងតាំងជាព្រះរាជអាជ្ញាតាំងពីឆ្នាំ១៩៧២ ហើយនៅក្នុងឆ្នាំ១៩៧៧ លោកបានទទួលការតែងតាំងជាចៅក្រម ដោយទទួលខុសត្រូវទាំងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌក្នុងរយៈពេល២៦ឆ្នាំបន្ទាប់ទៀត ។ ចាប់ពីឆ្នាំ ២០០៣ ដល់២០០៥ លោកចៅក្រម ប៊្លុង មានតួនាទីជាចៅក្រមអន្តរជាតិនៅក្នុងតុលាការកូនកាត់មួយដែលត្រូវបានបង្កើតឡើងដោយអង្គការសហប្រជាជាតិសម្រាប់ប្រទេសទីម័រខាងកើត ។[១៨] លោកត្រូវបានតែងតាំងជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីឆ្នាំ២០០៨ ហើយរហូតមកដល់ឆ្នាំ២០១០ លោកបានទទួលការតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ។[១៩] ក្រោយពេលទទួលបានការតែងតាំងជាសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ស៊ីកហ្វ្រេដ បានបន្តការស៊ើបអង្កេតលើសំណុំរឿង ០០៣ និង ០០៤ ។[២០] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង បានប្រកាសលាលែងពីមុខនាទីរបស់ខ្លួននៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ដោយបានផ្ញើលិខិតលាលែងទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការលាលែងនេះធ្វើឡើងបន្ទាប់ពីមានការរិះគន់ពីអង្គការសង្គមស៊ីវិលជាច្រើន ។ អង្គការអន្តរជាតិឃ្លាំមើលសិទ្ធិមនុស្ស *(Human Rights*

---

១៥ សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០, សូមមើល *www.eccc.gov.kh/sites/default/files/media/OCIJ-PR-9June2010(Kh).pdf* ។

១៦ អត្ថបទមានចំណងជើងថា “ឡឺមុង លើកឡើងនូវសំដីចុងក្រោយ” របស់ភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ។

១៧ អត្ថបទ “សាលាក្តីតែងតាំងលោក Siegfried Blunk ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី” កាសែតរស្មីកម្ពុជា ឆ្នាំទី៩ លេខ២៨១៨ ថ្ងៃសុក្រ ទី៣ ខែធ្នូ ឆ្នាំ២០១០ ។

១៨ លោក ស៊ីកហ្វ្រេដ ប៊្លុង ជាចៅក្រមអន្តរជាតិនៅប្រទេសទីម័រខាងកើត អស់រយៈពេលពីរឆ្នាំ មុនពេលដែលតុលាការត្រូវបានបិទ ។ នៅទីនោះលោកបានធ្វើការជាមួយប្រព័ន្ធតុលាការដែលមានលក្ខណៈជាតុលាការក្នុងស្រុកដូចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ហើយលោកបានធ្វើការជាមួយចៅក្រមជាតិ និងបុគ្គលិកជាតិរបស់ប្រទេសទីម័រខាងកើតដូចនៅកម្ពុជាដែរ ។ កាសែតភ្នំពេញប៉ុស្តិ៍ សូមមើល *www.cambodiatribunal.org/sites/default/files/news/krtjudgetalkscourtcontroversies.pdf* ។

១៩ ការិយាល័យសហចៅក្រមស៊ើបអង្កេត, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល *www.eccc.gov.kh/en/judicial-person/judge-siegfried-blunk* ។

២០ សេចក្តីថ្លែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល *www.eccc.gov.kh/articles/15689* ។

*Watch)* បានរិះគន់ថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការដោយអព្យាក្រឹតក្នុងសំណុំរឿង០០៣ និង០០៤ឡើយ ។[២១] នៅពេលលាលែងពីតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង បានធ្វើសេចក្តីថ្លែងការណ៍ដោយបានលើកឡើងពីសម្តីរបស់លោកនាយករដ្ឋមន្ត្រីកម្ពុជា ដែលជម្រាបជូនទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន ថា "នឹងមិនអនុញ្ញាតឲ្យមានសំណុំរឿងទាំងពីរនេះឡើយ" ។ មិនតែប៉ុណ្ណោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិរូបនេះបានលើកឡើងបន្ថែមទៀតពីសម្តីរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មានថា "ប្រសិនបើពួកគេចង់បន្តដំណើរការរឿងក្តី០០៣ និង០០៤ ពួកគេគួរតែរៀបចំអីវ៉ាន់ហើយចាកចេញ" ។ ហើយលោកបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសថា "ការចាប់ខ្លួនអតីតមេដឹកនាំខ្មែរក្រហមបន្ថែមទៀតគឺជារឿងរបស់កម្ពុជា ។ រឿងនេះត្រូវតែសម្រេចដោយកម្ពុជា ។ (កាសែតខែមបូឌា ដេលី ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១១)" ។ ចុងបញ្ចប់នៃសេចក្តីថ្លែងការណ៍នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេក ប៊្លុង បានលើកឡើងថា "ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនដាក់ខ្លួនឲ្យស្ថិតនៅក្រោមឥទ្ធិពលនៃការលើកឡើងខាងលើក៏ដោយ ក៏នៅតែមានមន្ទិលសង្ស័យទៅលើលទ្ធភាពរបស់លោកក្នុងការទ្រាំទ្រ និងសម្ពាធរបស់រដ្ឋាភិបាល និងលទ្ធភាពក្នុងការបំពេញការងារដោយឯករាជ្យហើយក៏បង្កឲ្យមានមន្ទិលសង្ស័យចំពោះសុចរិតភាពនៃដំណើរការទាំងមូលរបស់តុលាការនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែរ" ។[២២]


សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ យូ ប៊ុនឡេង និង ស៊ីកហ្វ្រេដ ប៊្លុង (រូបថត : អ.វ.ត.ក)

## ៣) ទស្សនៈជុំវិញការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប៊្លុង

### ក) ប្រតិកម្មពីសំណាក់អង្គការក្រៅរដ្ឋាភិបាល

ឆ្លើយតបនឹងការលាលែងពីតួនាទីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង *(Siegfried Blunk)* បណ្តាអង្គការអន្តរជាតិនានាបានបញ្ចេញនូវទស្សនៈមួយចំនួនជុំវិញការលាលែងនេះ ។

នៅថ្ងៃអង្គារ៍ទី១១ខែតុលា ឆ្នាំ២០១១ អង្គការលើកលែងទោសអន្តរជាតិ (*Amnesty International*) បានអំពាវនាវឲ្យ

[២១] លាង ដឺលុច, អត្ថបទសហចៅក្រមស៊ើបអង្កេតអន្តរជាតិលាលែងពីតួនាទីចុះផ្សាយថ្ងៃច័ន្ទ ទី១០ ខែតុលា ២០១១ វិទ្យុបារាំងអន្តរជាតិ www.khmer.rfi.fr/cambodia ។

[២២] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ការិយាល័យសហចៅក្រមស៊ើបអង្កេត, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh/articles/15689 ។

អង្គការសហប្រជាជាតិពារាំងកម្ពុជាកុំឲ្យលូកដៃចូលកិច្ចការតុលាការខ្មែរក្រហមខណៈពេលដែលរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាពន្យល់ថា រដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវចំពោះអស្ថិរភាពឬអសន្តិសុខសង្គម ។ លោកនាយកអង្គការលើកលែងទោសអន្តរជាតិប្រចាំអាស៊ីប៉ាស៊ីភិក Sam Zarifi បានថ្លែងថា វាជាការចំបាច់ដែលអង្គការសហប្រជាជាតិត្រូវមានវិធានការដើម្បីធានានាអនាគតរបស់សាលាក្តីដោយធានាថាដំណើរការសាលាក្តីនេះនឹងទទួលបានស្តង់ដារនៃការកាត់ក្តីយុត្តិធម៌ ដោយឯករាជ្យ និង អព្យាក្រឹត ។[២៣]

ទន្ទឹមនឹងនេះ លោកស្រី ក្លែ ដាហ្វ៊ី (Clair Duffy) អ្នកឃ្លាំមើលសាលាក្តីខ្មែរក្រហមនៃអង្គការច្បាប់របស់សហរដ្ឋអាមេរិកមួយមានឈ្មោះថា អង្គការផ្តួចផ្តើមយុត្តិធម៌សង្គមបើកទូលាយ (Open Society Justice Initiative) បានថ្លែងថា ការលាឈប់ពីតំណែង និងការជំនួសអ្នកថ្មីមិនមែនជាដំណោះស្រាយទេ ។ រឿងនេះអង្គការសហប្រជាជាតិនិង ប្រទេសកម្ពុជាត្រូវដោះស្រាយឲ្យបានប្រញាប់ ។ លោកស្រីបានលើក ឡើងថា «ខ្ញុំជឿជាក់ខ្លាំងណាស់ថារឿងនេះមិនមែនជាអ្វីដែលនឹងអាចដោះស្រាយបានទេ ។ ជាការពិតយើងនឹងឃើញបញ្ហាដូចគ្នានេះបង្ហាញពួកគេនៅពេលលើកទីបីជាមួយនឹងចៅក្រមស៊ើបអង្កេតអន្តរជាតិទីបីនៅក្នុងមុខតំណែងនេះ ។ ជារឿងចាំបាច់រដ្ឋាភិបាលកម្ពុជានិង អង្គការសហប្រជាជាតិត្រូវតែអង្គុយប្រជុំនៅតុជាមួយគ្នាដើម្បីពិភាក្សាដោយស្មោះត្រង់អំពីគោលបំណងណាមួយដែលពួកគេចង់ឃើញ ហើយថាតើកេរ្តិ៍ឈ្មោះយ៉ាងម៉េចដែលគេចង់ឃើញនៅទីបញ្ចប់នៃតុលាការនេះ» ។[២៤]

## ១) ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា

ដោយមានការលើកឡើងជាច្រើនពាក់ព័ន្ធទៅនឹងការលាលែងចេញពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង រដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវគោលជំហររបស់ខ្លួននៅក្នុងការលើកឡើងពីការជ្រៀតជ្រែកសាលាក្តីខ្មែរក្រហម ។ នៅថ្ងៃអង្គារទី ១១ ខែតុលា ឆ្នាំ២០១១ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសមានប្រសាសន៍ប្រាប់អ្នកយកព័ត៌មានថា កម្ពុជាគាំទ្រសេចក្តីសម្រេចជាក់លាក់ទាំងឡាយរបស់សាលាក្តីខ្មែរក្រហម ។ លោកបានលើកឡើងថា «ដល់សរុបមកជាសិទ្ធិរបស់តុលាការ ។ ប្រសិនក្នុងនាមជាអ្នកដឹកនាំប្រទេសជាតិទទួលជួបជោគវាសនារបស់ប្រទេសជាតិរបស់ប្រជាជន ។ យើងមានយោបល់ដូច្នេះ អ្វីៗស្រេចតែលើតុលាការ ។ សូមអរគុណ» ។ ឯកឧត្តម ហោ ណាំហុង បានបកស្រាយថា មានការបកស្រាយខុសទៅលើសេចក្តីថ្លែងការណ៍របស់លោក ក៏ប៉ុន្តែលោកក៏បានបញ្ជាក់ថា រដ្ឋាភិបាលមានបុព្វសិទ្ធិអំពីការចោទសួរទៅលើចំណោទដែលអាចកើតឡើងពីចំណាត់ការរបស់តុលាការ ។ «យើងដឹងច្បាស់ការ ស្រាវជ្រាវរកសំណុំរឿងទី៣ និងទី៤ជាសិទ្ធិរបស់តុលាការ ។ ក្នុងឋានៈជារដ្ឋាភិបាលទទួលខុសត្រូវជោគវាសនារបស់ជាតិ បើសិនជាតុលាការកូនកាត់នេះធ្វើអ្វីមួយដែលនាំឲ្យមានអសន្តិសុខ គឺសង្គ្រាមនៅកម្ពុជា ។ តើអ្នកណាទទួលខុសត្រូវ?»[២៥]

ជាមួយគ្នានេះដែរ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃបានសរសេរលិខិតបំភ្លឺមួយទៅកាន់កាសែតបាងកកប៉ុស្តិ៍របស់ថៃចំពោះអត្ថបទដែលមានចំណងជើងថា «ចៅក្រមលាលែងដោយសារតែការជ្រៀតជ្រែករបស់រដ្ឋាភិបាល» ។ ក្នុងលិខិតចុះថ្ងៃពុធ ទី១២ ខែតុលា ឆ្នាំ ២០១១ លោកស្រី យូ អយ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃដោយលោកស្រីបានលើកឡើង

[២៣] លាង ដឹលុច, អត្ថបទ ប្រតិកម្មជុំវិញសំណុំរឿង០០៣ និង០០៤ ចុះផ្សាយថ្ងៃអង្គារ៍ ទី១១ ខែតុលា ឆ្នាំ០១១ វិទ្យុបារាំងអន្តរជាតិ www.khmer.rfi.fr/amnesty_call_UN_to_tell_cambodian_govt_not_to_involve_in_khmerrouge_trial ។

[២៤] សុខ ខេមរា, អត្ថបទ ក្រោយពីចៅក្រមលាលែងក្រុមអ្នកសង្កេតការណ៍ស្នើឲ្យអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលពិភាក្សាគ្នា ដោយកុំឲ្យមានសម្ពាធនយោបាយ ចុះផ្សាយថ្ងៃច័ន្ទទី១០ ខែតុលា ២០១១ សំឡេងសហរដ្ឋអាមេរិក www.voanews.com/khmer/news ។

[២៥] គង់ សុឋានរិទ្ធ, អត្ថបទរដ្ឋាភិបាលកម្ពុជាបញ្ជាក់ពីជំហររបស់ខ្លួនរឿងការជ្រៀតជ្រែកសាលាក្តីខ្មែរក្រហម ចុះផ្សាយថ្ងៃអង្គារ៍ទី១១ ខែតុលា ឆ្នាំ២០១១ សំឡេងសហរដ្ឋអាមេរិក www.voanews.com/khmer/news ។

ថារដ្ឋាភិបាលកម្ពុជាយល់ច្បាស់ថា វាជាបុព្វសិទ្ធិរបស់សាលាក្ដីចម្រុះកាត់ទោសមេខ្មែរក្រហមដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចចិត្តចោទប្រកាន់បុគ្គលណាម្នាក់នៅពីក្រោយបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអំឡុងរបបខ្មែរក្រហម ។ លោកស្រីឯកអគ្គរាជទូតបានបញ្ជាក់ទៅកាន់កាសែតបាងកកប៉ុស្ដិ៍ថា ចាប់តាំងពីពេលបង្កើតសាលាក្ដីចម្រុះនោះមកដល់សព្វថ្ងៃរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវការគោរពដោយពេញលេញលើឯករាជ្យភាពនៃដំណើរការកាត់ទោសមេខ្មែរក្រហម និងមិនដែលជ្រៀតជ្រែកចំពោះដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះខ្មែរឡើយ ។ ហើយលោកស្រីបានបញ្ជាក់ទៀតថា រដ្ឋាភិបាលកម្ពុជាចង់ឲ្យតុលាការកូនកាត់បំពេញបេសកម្មរបស់ខ្លួនឲ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ពីព្រោះអតីតមេខ្មែរក្រហមទាំងបួនរូបដែលកំពុងជាប់ឃុំឃាំងនៅក្នុងសំណុំរឿង០០២កាន់តែមានវ័យចំណាស់ និងមានជំងឺ ហើយអាចនឹងស្លាប់នៅពេលណាមួយ ។ ដូច្នេះសាលាក្ដីចម្រុះអាចនឹងប្រឈមមុខក្នុងការមិនបានកាត់ទោសមេដឹកនាំខ្មែរក្រហមណាម្នាក់ ប្រសិនបើដំណើរការកាត់ទោសត្រូវអូសបន្លាយ ។ មិនតែប៉ុណ្ណោះលោកស្រីបានបញ្ជាក់បន្ថែមថា នៅក្នុងរឿងសាលាក្ដីខ្មែរក្រហមរដ្ឋាភិបាលកម្ពុជាគ្រាន់តែបង្ហាញនូវក្ដីបារម្ភរបស់ខ្លួនចំពោះការផ្សះផ្សារជាតិ សន្តិភាព សន្តិសុខ និងការអភិវឌ្ឍជាតិ បើសិនមានការចោទប្រកាន់បន្ថែមលើអតីតមេខ្មែរក្រហម ។[២៦]

## ក) ប្រតិកម្មពីអង្គការសហប្រជាជាតិ

នៅក្នុងសប្ដាហ៍បន្ទាប់នៃការលាលែងពីមុខនាទីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លោក ស៊ីកហ្វ្រេដ ប៊្លុង *(Siegfried Blunk)* អង្គការសហប្រជាជាតិបានបញ្ជូនអគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកកិច្ចការច្បាប់មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាដើម្បីស្វែងរកដំណោះស្រាយមួយចំពោះរឿងសាលាក្ដីខ្មែរក្រហម ។ កាលពីថ្ងៃព្រហស្បតិ៍ ទី២០ ខែតុលា ឆ្នាំ ២០១១ លោក ស្រី ប៉ាទ្រីស្យា អូប្រាយអិន *(Patricia O'Brien)* ដែលជាអគ្គលេខាធិការរងអង្គការសហប្រជា



ក្រុមនិស្សិតកំពុងយកឯកសារមុនចូលបន្ទប់សវនាការ ខែតុលា ឆ្នាំ២០១១ (ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

[២៦] លី ម៉េងហួរ, អត្ថបទ ទូតកម្ពុជាប្រចាំប្រទេសថៃបញ្ជាក់ថា រដ្ឋាភិបាលមិនជ្រៀតជ្រែកដំណើរការតុលាការខ្មែរក្រហម ចុះផ្សាយថ្ងៃពុធ ទី១២ ខែតុលា ឆ្នាំ២០១១ វិទ្យុបារាំងអន្តរជាតិ *www.khmer.rfi.fr* ។

ជាតិ ទទួលបន្ទុកផ្នែកកិច្ចការច្បាប់បានជួបពិភាក្សាការងារជាមួយលោកឧបនាយករដ្ឋមន្ត្រី សុខ អាន នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ ការជួបពិភាក្សាការងាររបស់លោកស្រី ប៉ាទ្រីស្យា អូប្រាយអិន និងលោកឧបនាយករដ្ឋមន្ត្រី សុខ អាន គឺដើម្បីពិភាក្សាកង្វល់របស់អង្គការសហប្រជាជាតិអំពីការវិវឌ្ឍថ្មីៗ នៅសាលាក្តីខ្មែរក្រហមបន្ទាប់ពីការលាឈប់របស់លោក ស៊ីកហ្វ្រេដ ប៊្លុង សហចៅក្រមស៊ើបអង្កេតភាគីខាងអង្គការសហប្រជាជាតិកាលពីសប្តាហ៍មុន ។ លោកស្រីបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ថា លោកស្រីបានជំរុញយ៉ាងខ្លាំងឲ្យរាជរដ្ឋាភិបាលកម្ពុជាឈប់ចេញសេចក្តីថ្លែងការណ៍ទាំងឡាយដែលប្រឆាំងនឹងការរីកចម្រើននៃសំណុំរឿងលេខ០០៣ និង០០៤ ហើយឲ្យឈប់ជ្រៀតជ្រែកតាមវិធីណាក៏ដោយក្នុងដំណើរការវិនិច្ឆ័យ ។[២៧]

**ឃ) ប្រតិកម្មរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទចំពោះការលាលែងពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ដែលរួមមានលោកមេធាវីអន្តរជាតិ ម៉ៃឃើល ភីសមែន និងលោក អេនឌ្រូ អៀនូហ្ស៊ី (Andrew Ianuzzi) បានដាក់ពាក្យប្តឹងទៅកាន់តុលាការក្រុងភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ។[២៨] នៅក្នុងពាក្យបណ្តឹងនេះ មេធាវីទាំងពីរបានប្តឹងលោក ជា ស៊ីម, ហេង សំរិន, ហោ ណាំហុង, គាត ឈន់, អ៊ុក ប៊ុនឈឿន, ស៊ីម កា, ខៀវ សុភ័គ, ហ៊ុន សែន, ខៀវ កាញារីទ្ធ, ផៃ ស៊ីផាន និង គង់ សំអុល ដោយផ្អែកលើមាត្រា៤៣និង៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។[២៩] លោកមេធាវីបានលើកឡើងថា « ពាក្យបណ្តឹងប្តឹងថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាមួយចំនួន ដោយជារូបវន្តបុគ្គល និងតាមរយៈការចូលរួមរបស់ពួកគេដែលជាចេតនាទុច្ចរិតទូទៅត្រូវមានពិរុទ្ធភាពពីបទជ្រៀតជ្រែកចូលវិស័យតុលាការ និងសិទ្ធិរបស់ជនជាប់ចោទក្នុងទទួលបានការកាត់ក្តីដោយត្រឹមត្រូវ និងយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៣០]

**ង) សហចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកឡើងពីបញ្ហារបស់សហចៅក្រមស៊ើបអង្កេត**

មិនតែប៉ុណ្ណោះ ក្រោយពេលមានការលាលែងចេញពីមុខនាទីនេះនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាមួយទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមិល ។[៣១]

សហចៅក្រមអន្តរជាតិ រ៉ូវ៉ាន់ ដននីង (Rowan Downing) និង កាត់ទីនកា ឡាហ៊ឺស (Katinka Lahuis) មានការខ្វែងយោបល់គ្នាជាមួយសហភាគាដែលជាចៅក្រមជាតិទាំងបីរូបលើការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដោយរកឃើញថាសហចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រេដ ប៊្លុង និងចៅក្រម យូ ប៊ុនឡេង បានប្រព្រឹត្តខុសប្រក្រតីនៃនីតិវិធី ដោយរួមបញ្ចូលទាំងការចុះកាលបរិច្ឆេទថយក្រោយលើឯកសារ ការកែប្រែឯកសាដោយសម្ងាត់ និងខកខានក្នុងការជូនដំណឹងឲ្យបានត្រឹមត្រូវទៅកាន់

[២៧] ជន សក្កា, អត្ថបទ មន្ត្រីជាន់ខ្ពស់អង្គការសហប្រជាជាតិព្រមានមិនឲ្យមន្ត្រីរដ្ឋាភិបាលជ្រៀតជ្រែកកិច្ចការតុលាការខ្មែរក្រហម ចុះផ្សាយថ្ងៃសុក្រ ទី២១ ខែតុលា ឆ្នាំ២០១១ សំឡេងសហរដ្ឋអាមេរិក www.voanews.com/khmer/news ។
[២៨] កាសែត ឌឺ ខេមបូឌា ដេលី អត្ថបទស្តីពី « នួន ជា ដាក់ពាក្យចោទប្រកាន់ពីការជ្រៀតជ្រែកទៅតុលាការ » ចុះផ្សាយថ្ងៃច័ន្ទ ទី២៤ ខែតុលា ឆ្នាំ២០១១ ។
[២៩] បណ្តឹងព្រហ្មទណ្ឌរបស់លោក ម៉ៃឃើល ភីសមែន និង លោក អេនឌ្រេនូហ្សេ ដែលបានដាក់ជូនការិយាល័យព្រះរាអាជ្ញា កថាខណ្ឌ១០ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ។
[៣០] កាសែត ឌឺ ខេមបូឌា ដេលី អត្ថបទស្តីពី « មេធាវីការពារក្តីឲ្យ នួន ជា ប្តឹង ហ៊ុន សែន និង បុគ្គល១០រូបទៀត » ចុះផ្សាយថ្ងៃច័ន្ទទី២៤ ខែតុលា ឆ្នាំ២០១១ ។
[៣១] ឯកសារតុលាការ លេខ D11/2/4/4 ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមមើល www.eccc.gov.kh/document/court/15810 ។

មេធាវី ។[៣២]

ឆ្លើយតបនឹងការលើកឡើងរបស់សហចៅក្រមអន្តរជាតិទាំងពីរ នៅអង្គបុរេជំនុំជម្រះដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រេដ ប៊ុង និង យូ ប៊ុនឡេង បានប្រព្រឹត្តខុសប្រក្រតីនៃនីតិវិធីសហចៅក្រមស៊ើបអង្កេតបានធ្វើការប្រកាសព័ត៌មានជាសាធារណៈកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ថា ព័ត៌មានមួយចំនួនត្រូវបានចុះនៅក្នុងបណ្តាញសារព័ត៌មានទាក់ទិននឹងសហចៅក្រមស៊ើបអង្កេត ជាពិសេសទាក់ទិននិងការណ៍ដែល "...សហចៅក្រមស៊ើបអង្កេតទាំងពីរបានចុះកាលបរិច្ឆេទថយក្រោយ និងបានកែប្រែជាសមាត់នូវឯកសារដែលបានដាក់ចូលក្នុងសំណុំរឿង ០០៣..." ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយយោងទៅលើសហចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ) ទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់អ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ។[៣៣] សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ខ្លួនបានធ្វើទៅតាមនីតិវិធីទាំងការកែប្រែឯកសារ និងការជូនដំណឹងទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ។ សហចៅក្រមស៊ើបអង្កេតក៏បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើការកែប្រែលើកាលបរិច្ឆេទនៃដីកាចេញសេចក្តីសម្រេចរបស់ខ្លួននោះទេ ហើយចំពោះនីតិវិធីជូនដំណឹងទៅកាន់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺបានអនុវត្តទៅតាមធម្មតា ។[៣៤]

ចំពោះការលេចឡើងនូវព័ត៌មានពាក់ព័ន្ធទៅនឹងភាពខ្វះចន្លោះរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា បានធ្វើសំណើបញ្ជីសម្ភារៈដែលជិតដាមនឹងរឿង ០០២ និងស្នើសុំឲ្យលាឈប់ពីការងារ ។ សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា រួមមានលោក ភីសមែន និងលោក វិកទ័រ គូប៉េ (Victor Koppe) និងលោក អេនឌ្រូ អៀនូហ្វ៊ី និងលោក ហ្សាស្ទីរ ប៉ោ បានធ្វើសំណើសុំតាមរយៈសាអេឡិចត្រូនិច ដើម្បីសុំពិនិត្យឯកសារនិងភស្តុតាងនានា ហើយបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង ធ្វើការលាលែងពីតំណែង ។

ឆ្លើយតបចំពោះការលាលែងនេះដែរសហចៅក្រមស៊ើបអង្កេតជាតិ លោក យូ ប៊ុនឡេង មិនបានបញ្ចេញទស្សនៈអ្វីច្រើននេះទេ លោកបានលើកឡើងថា ការលាលែងរបស់សហចៅក្រមអន្តរជាតិនេះគឺជារឿងមួយដែលភ្ញាក់ផ្អើលបំផុតសម្រាប់រូបលោក ។ លោកបានបញ្ជាក់ទៀតថា នាពេលកន្លងមកនេះ ទំនាក់ទំនងការងាររវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិនិងរូបលោកដែលជាសហចៅក្រមស៊ើបអង្កេតជាតិបានដំណើរការទៅយ៉ាងរលូនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍ច្បាប់ និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាមូលដ្ឋាន បើទោះជាមានការចោទប្រកាន់តាមរយៈការបំផ្លើសព័ត៌មានប្រាសចាកពីការពិតពីមជ្ឈដ្ឋានខាងក្រៅមួយចំនួនក៏ដោយ ។[៣៥]

ថ្វីដ្បិតតែការលាលែងពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេតគឺជាសិទ្ធិរបស់ចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ប៉ុន្តែតាមរយៈសេចក្តីថ្លែងការណ៍របស់លោកបានបង្កើតឲ្យមានការដេញដោល និងការពិភាក្សាជាច្រើនទៅលើបញ្ហាអព្យាក្រិត្យ យុត្តិធម៌ និងតម្លាភាពរបស់សាលាជម្រះក្តីមេដឹកនាំខ្មែរក្រហម ពិសេសគឺឯករាជ្យភាពរបស់តុលាការខ្មែរក្រហម ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ ខ៊ាន់ថាន់ ពៅដារ៉ា**

---

៣២ កាសែត ឌឺ ខេមបូឌា ដេលី អត្ថបទស្តីពី "ចៅក្រមនៅសាលាក្តីកាត់ទោសខ្មែរក្រហមរៀបរាប់ពីភាពខ្វះចន្លោះរបស់ ប៊ុង និង ប៊ុនឡេង" ចុះផ្សាយថ្ងៃច័ន្ទ ទី២៦ ខែតុលា ឆ្នាំ២០១១ ។

៣៣ សេចក្តីប្រកាសព័ត៌មានរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ សូមមើល www.eccc.gov.kh/media-center/press-releases ។

៣៤ ដូចខាងលើ ។

៣៥ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការិយាល័យសហចៅក្រមស៊ើបអង្កេត សូមមើល www.eccc.gov.kh/articles/15702 ។

មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល ៖ dccam@online.com.kh
គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org


គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ
John D. and Catherine T. MacArthur Foundation ។




**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**គីម ម៉ារីយ៉ាន**

**ម៉ារីយ៉ាន** បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ម៉ារីយ៉ាន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**លីម ជ័យទត្ត**

**ជ័យទត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ចាន ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។


អៀង សារី
មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែកញ្ញា ឆ្នាំ២០១១